Document Produced by deskPDF Unregistered :: http://www.docudesk.com

## ពាក្យថាម៉ែ

ពាក្យថា " ម៉ែ " ជាពាក្យដែលមានអត្ថន័យសំខាន់ណាស់ ជាពាក្យដែលពីរោះ សើមជ្រួតជ្រាបចូលក្នុងចិត្តរបស់កូនគ្រប់គ្នា ព្រោះម៉ែជាអ្នកមានព្រះគុណដ៏យ៉ាងធំក្រៃលែង គឺជាអ្នកឱ្យនូវជីវិត ឱ្យសេចក្តីស្រឡាញ់ ឱ្យទ្រព្យសម្បត្តិ ឱ្យបានទទួលការសិក្សា។ ម៉ែជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូន និងជាអ្នកនៅជិតកូនច្រើនជាងអ្នកណាៗទាំង-អស់ ទាំងពាក្យថា "ម៉ែ" គឺ ជាពាក្យដែលមនុស្សយើងនិយាយបានមុនពាក្យដទៃទៀតនៅក្នុងជីវិតនេះ ។

ពាក្យម៉ែមានន័យសំខាន់ខ្លាំងណាស់ ប្រជុំគុណក្រាស់ក្រៃជាងធរណី
ពាក្យម៉ែពីរោះគ្រប់លើប្រឹថពី ល្អដូចគីរីពេញដោយរុក្ខា ។
ព្រៃធំមានសត្វជាគ្រឿងលម្អ ភរិយាបវរលម្អភស្តា
ទ្វីបលោកល្អស្រស់ក៏ព្រោះសុរិយា សត្វក្នុងលោកាល្អព្រោះមានម៉ែ។



## ភារៈធ្ងន់របស់ម៉ែ

កាលបើពោលតាមច្បាប់ធម្មជាតិ ឬពោលតាមសេចក្តីពិតដែលប្រាកដឱ្យឃើញ ម៉ែឈ្មោះថាធ្វើនូវរបស់ដែលធ្វើបានដោយលំបាក ហើយសេចក្តីលំបាកនេះ ឪពុកមិនអាចធ្វើជំនួសបានឡើយ ពោលគឺ **ម៉ែត្រូវចាក់រង្គូវ ត្រូវពពោះ** និង **ត្រូវឆ្លងទន្លេ** (សម្រាលកូន) នេះគឺជាសេចក្តីទុក្ខលំបាករបស់ម៉ែគ្រប់គ្នា ក្នុងនោះ មានម៉ែមិនតិចនាក់ទេ ដែលត្រូវបានបាត់បង់ជីវិត ព្រោះការឆ្លងទន្លេ ។

ព្រោះហេតុដូច្នេះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក្នុងកាលដែលព្រះអង្គនៅជាព្រះមហាពោធិសត្វ សោយព្រះ-ជាតិជាតាបសឈ្មោះ **សោណបណ្ឌិត** បានពណ៌នាព្រះគុណរបស់ម៉ែយ៉ាងគួរស្តាប់ មានប្រាកដក្នុងសោណនន្ទជាតក សត្តតិនិបាត ថា :

ម៉ែកាលប្រាថ្នាចង់បានផលគឺកូន រមែងនមស្ការទេវតាដើម្បីសូមកូន ម៉ែសួរនូវនក្ខត្តឫក្សទាំងឡាយផង

Document Produced by deskPDF Unregistered :: http://www.docudesk.com

ស្ទូវនូវរដូវ និងឆ្នាំទាំងឡាយផង ថាតើកូនកើតក្នុងឫក្សណា ក្នុងរដូវណា ក្នុងឆ្នាំណា ទើបបាននូវអាយុវែង ។

កាលម៉ែមានរដូវហើយ ក៏រមែងមានការតាំងគភ៌ឡើង ហើយម៉ែក៏មានការចាញ់គភ៌ ព្រោះហេតុនោះទើបម៉ែមានឈ្មោះថា **ទោហឡិនី** (ស្ត្រីចាញ់គភ៌) ។

ម៉ែមានការស្រឡាញ់កូន ដែលកើតក្នុងពោះរបស់ខ្លួន ព្រោះហេតុនេះទើបម៉ែមានឈ្មោះថា **សុហទា** (ស្ត្រីមានចិត្តល្អ)។

ម៉ែរក្សាគភ៌អស់មួយឆ្នាំ ឬជិតមួយឆ្នាំ ហើយទើបបានឆ្លងទន្លេសម្រាលកូន ព្រោះហេតុនេះ ទើបម៉ែមានឈ្មោះថា **ជនយន្តី** ឬ **ជនេត្តី** (ស្ត្រីជាអ្នកឱ្យកូនបានកើតមក)។

ម៉ែញាំងកូនដែលកំពុងយំឱ្យត្រេកអរ ដោយការបំបៅដោះផង ដោយការបំពេផង ដោយការឱបក្រសោបផង ព្រោះហេតុនេះ ទើបម៉ែមានឈ្មោះថា **តោសេន្តី** (ស្ត្រីញាំងកូនឱ្យត្រេកអរ) ។



តពីនោះមកម៉ែមានហឫទ័យទន់ទោរទៅរកកូន ក្រឡេកមើលកូនដែលពុំទាន់ដឹងក្តី មើលក្នុងទីដែលកូននៅ ត្រូវខ្យល់ត្រូវក្តៅយ៉ាងណា ព្រោះហេតុនេះ ទើបម៉ែឈ្មោះថា **ពោសេន្តី** (ស្ត្រីអ្នកចិញ្ចឹមបីបាច់ថែរក្សាកូន)។

ទ្រព្យសម្បត្តិឯណារបស់ម៉ែនិងរបស់ឪ ដែលមាននៅ ម៉ែរមែងគ្រប់គ្រងនូវទ្រព្យសម្បត្តិទាំងពីរចំណែកនោះ ដោយបំណងថា ទ្រព្យសម្បត្តិទាំងនេះត្រូវបានទៅកូនរបស់យើង ។

ម៉ែកាលដែលទូន្មានកូនថា កូនគួរធ្វើយ៉ាងនេះ កូនមិនគួរធ្វើយ៉ាងនោះ ជាដើម រមែងនឿយហត់លំបាក ។

កាលបើកូនមានវ័យចម្រើនឡើងហើយ ម៉ែបានដឹងថា កូនមានសេចក្តីរីករាយភ្លើតភ្លើនព្រោះស្រវឹងក្នុងវ័យ ។ ម៉ែរមែងទន្ទឹងមើលផ្លូវកូន លុះដល់ពេលល្ងាចពេលព្រលប់ បាត់កូនមិនឃើញត្រឡប់មក ម៉ែក៏អន្ទះសាញាប់ញ័រក្នុងចិត្ត ដោយប្រការ ដូច្នេះឯង ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

# ព្រះគុណម៉ែ

គុណម៉ែតាំងតែគភ៌ចាប់ផ្ដើម ទ្រាំពពោះផើមទ្រាំលំបាក
ដេកដើរដូចរោគតាមឥតស្រាក ទម្រាំកូនចាកចេញពីផ្ទៃ។
ពេលឆ្លងទន្លេម៉ែឈឺខ្លាំង ចិត្តតាំងកាយប្រឹងព្រមដោយភ័យ
មិនដឹងយ៉ាងណាចិត្តមមៃ នឹកភ័យក្រែងកូនសូន្យសង្ខារ។
លុះកូនបានកើតជាទារក ម៉ែថើបជញ្ជក់សព្វកាយា
បីបមថ្នាក់ថ្នមពេញហត្ថា មេត្តាប្រែឈាមជាទឹកដោះ។
នៅពេលកូនឈឺម៉ែរក្សា បីផ្ចប់ឱរាដោយចិត្តស្មោះ
កូនឈឺម៉ែភ័យមុខស្លាំងអស់ មិនសម្រាន្តសោះវាស់ៗព្រឹក។
នៅពេលកូនជាម៉ែសប្បាយ ចិត្តម៉ែមិនណាយមានតែនឹក
ឃ្លាតឆ្ងាយបន្តិចចិត្តវរវឹក រលឹករកកូនវិលវិញភ្លាម ។
អង្គុយកកិលក្រោកឈរដើរ ទៅតាមដំណើរម៉ែព្យាយាម
ខំបង្ហាត់កូនដោយមិនទាម ក្នុងនាមជាគ្រូឧត្ដមក្រៃ ។



ជុះនោមហូបចុកស្លៀកដណ្ដប់ ចំណេះចេះសព្វប្រចាំថ្ងៃ
សម្ដីភាសាមារយាទថ្លៃ កូនកុំសង្ស័យក្រែងឥតគ្រូ ។
កូនចេះមួយមុខម៉ែអរម្ដង អួតប្រាប់អ្នកផងមិនចាំយូរ
ម៉ែនឿយយ៉ាងណាមិនគិតគូរ បន្ធូរកង្វល់ដោយថ្ពាល់កូន។
កូនធំបន្តិចបែបរាងរឹង កូនខ្លះទទឹងអាងជីដូន
ម៉ែខឹងអន់ចិត្តមុខស្រពោន វាយកូនរួចគិតអាណិតក្រោយ។
កូនល្អម៉ែសុខក្រៃកន្លង បានដូចម៉ែផ្សងសូមអំណោយ
ដូចបានកែវទិព្វទេវតាឱ្យ ឬដូចបានសោយសុខសួគ៌ា។
ពេលកូនបានសុខម៉ែសុខផង ពេលកូនមានហ្មងម៉ែពុំជា
កូនក្រលំបាកម៉ែរងា គ្រប់គ្រាម៉ែគិតកូនស្រីប្រុស។
កូនខូចអាក្រក់ក្នុងភូមិឃុំ គេគុំគេស្អប់សព្វសាយសុស
ម៉ែដឹងប្រាកដថាកូនខុស តែម៉ែសន្ដោសប្រោសប្រណី។
ម៉ែគឺជាព្រះរបស់កូន ជាក្បូនជីវិតមនុស្សប្រុសស្រី
ម៉ែមានគុណធ្ងន់ហួសពោលស្ដី គ្មានអ្វីជំនួសម៉ែបានឡើយ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

## ម៉ែគឺជាព្រះក្នុងផ្ទះ

ម៉ែជាអ្នកឱ្យសេចក្ដីស្រឡាញ់ ឱ្យការកក់ក្ដៅ ជាអ្នកគ្រប់គ្រង ធ្វើឱ្យកូនគ្រប់គ្នាមានសេចក្ដីដឹងខ្លួនថា អាត្មាអញមានការកក់ក្ដៅក្នុងចិត្តត្បិតមានម៉ែនៅជាមួយ ។

ម៉ែគឺជាមិត្តដ៏ពិតប្រាកដ មិនថាក្នុងពេលសុខ ឬពេលទុក្ខឡើយ ទោះបីកូនខុសឆ្គាំឆ្គងយ៉ាងណា ម៉ែតែងឱ្យអភ័យជានិច្ច ម៉ែជាទីប្រឹក្សាដ៏ល្អ និងជាទីទុកចិត្តសម្រាប់កូន ព្រោះហេតុដូច្នេះហើយ ទើបម៉ែបានទៅជាព្រះក្នុងផ្ទះ ។

ម៉ែជាអាចារ្យ ម៉ែជាទេវតា ស្ថិតនៅក្នុងផ្ទះ
និងម៉ែជាព្រហ្ម ព្រមទាំងជាព្រះ កូនក្រាបសំពះ
ឈ្នះអស់សត្រូវ ។



## ពេលឈឺធ្ងន់ច្រើនតែគិតដល់ម៉ែ

មនុស្សយើងដោយទូទៅ នៅពេលខ្លះអាចភ្លេចគិតដល់ម៉ែ ព្រោះរវល់តែសប្បាយរីករាយទៅដោយកាមគុណ ឬរវល់នៅក្នុងការងាររបស់ខ្លួនផ្សេងៗ ប៉ុន្តែដល់ពេលដែលខ្លួនឯងមានជំងឺធ្ងន់អ្វីមួយ កូនគ្រប់គ្នាច្រើនតែគិតរកម៉ែ ព្រោះធ្លាប់ជំពាក់ចិត្តនឹងម៉ែកាលពីខ្លួននៅតូច ។

ក្នុងសម័យដែលខ្លួនជាកូននៅតូច កាលបើឈឺចាប់អ្វីៗ ម៉ែតែងតែនៅថែរក្សាថ្នាក់ថ្នមជានិច្ច កូនឃើញមុខម៉ែជាប្រចាំ ម៉ែហួងហែងកូន ម៉ែសម្រាន្តមិនពេញភ្នែក ម៉ែទ្រាំអត់ងងុយនៅយាមកូន បបោសអង្អែលកូន នៅចាំពេលឱ្យបាយឱ្យទឹក នៅចាំពេលឱ្យថ្នាំ និងនៅចាំជួយកូនគ្រប់យ៉ាងពេលដែលកូនឈឺលំបាក ព្រមទាំងលួងលោមចិត្តកូនដោយសន្យាឱ្យនូវអ្វីៗ តាមដែលកូនចង់បានទៀតផង ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

ម៉ែជាទីពឹងរបស់កូន ពេលដែលកូនមានទុក្ខលំបាក សូម្បីកូនមានរូបរាងអបលក្ខណ៍យ៉ាងណាក្តី ម៉ែក៏នៅតែស្រឡាញ់ព្រមដោយក្តីអាណិតជានិច្ច ។ សេចក្តីស្រឡាញ់របស់ម៉ែ គឺជាសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ ដូច្នេះហើយទើបដល់ពេលដែលកូនមានជំងឺធ្ងន់ ឬក៏ពេលដែលត្រូវសម្រាលកូនឆ្លងទន្លេ កូនតែងតែនឹករកម៉ែ ។

ត្រីនៅលើគោកបម្រះរកទឹក    ចចកតែងនឹករកព្រៃស្មសាន
សត្វក្នុងទ្វីបលោកនឹករកសុខសាន្ត    មិនអាចប្រៀបបានចិត្តម៉ែដែលនឹក។
នៅពេលភ្លៀងធ្លាក់រុក្ខជាតិខៀវខ្ចី    បក្សាបក្សីខ្មៀវខ្មារពេលព្រឹក
ថ្ងៃក្តៅសត្វរកជ្រកក្រោមសន្លឹក    ប្រៀបដូចកូននឹករកម៉ែពេលឈឺ។



# ម៉ែមានព្រះគុណគូជាមួយឪ

មនុស្សយើងដែលកើតមក ត្រូវអាស្រ័យឪពុកនិងម្តាយជាអ្នកឱ្យកំណើត នឹងមានតែម្តាយម្នាក់ឯងពុំបានឡើយ ព្រោះតំណក់ឈាមមួយចំណែកបានពីម៉ែ តំណក់ឈាមមួយចំណែកទៀតបានពីឪ លោកទាំងពីរជាអ្នកឱ្យកំណើតដល់កូន និងជាអ្នកមាននូវគុណូបការៈដ៏យ៉ាងខ្ពង់-ខ្ពស់ចំពោះកូន ដូច្នេះ មាតាបិតា គឺជាព្រះឱ្យកំណើតកូន និងជាព្រះដ៏មានគុណចំពោះកូន ។

ផ្កាឈូកដែលដុះរីកស្រស់សោភា    អាស្រ័យគង្គារួមគ្នានឹងភក់
គូព្រេងជួបភក្ត្រវិលវល់វីរវក់    រួមរក្សលង់លក់បង្កើតលោកា។
ព្រហ្មចុះជួបព្រះសំពះវន្ទា    ក្រាបអារាធនាឱ្យទ្រង់ទេសនា
ព្រហ្មបានជួបព្រះកើតគុណអស្ចារ្យ    មាតាបិតាជាគូគុណគាប់ ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

# ក្មួនម៉ែត្រូវខំរៀន

ម៉ែសូមឱ្យកូនតាំងចិត្តរៀនដោយល្អ គ្រប់វិជ្ជាទាំង-អស់ដែលជាវិជ្ជាមានប្រយោជន៍ ។ ម៉ែសូមឱ្យកូនអស់ប្រាក់ក្នុងការដូរយកនូវចំណេះវិជ្ជា ។ ប្រាក់នោះឯង បើមិនអស់ទៅដើម្បីការបាននូវចំណេះវិជ្ជាទេ ក៏ត្រូវអស់ទៅក្នុងផ្លូវដទៃដែរ ដូចជា ការប្រើប្រាស់សម្លៀកបំពាក់ ការបរិភោគចំណីអាហារជាដើម តែរបស់នោះមិនមានតម្លៃដូចវិជ្ជាទេ ថែមទាំងមិនឋិតថេរយឺនយូរទៀតផង ។ ឯចំណែកវិជ្ជាវិញ ជារបស់ឋិតថេរជាប់តាមខ្លួនកូនរហូតមួយជីវិត ប្រើប៉ុនណាក៏មិនចេះអស់ រឹតតែជីករឹតតែជួបរឹតតែស្រាវជ្រាវរឹតតែចេះ រឹតតែប្រើរឹតតែជំនាញ ដូច្នេះការចាយវាយប្រាក់ដូរយកនូវចំណេះចេះដឹង ទើបបណ្ឌិតពោលសរសើរ ។

ម៉ែសូមឱ្យកូននឹករលឹកជានិច្ចថា ប្រាក់មួយរយៗ



នោះគឺជាតំណក់ញើសឈាមរបស់ម៉ែឪដែលខំប្រឹងធ្វើការ។ ម៉ែសូមឱ្យកូនយល់ដឹងក្នុងការចាយប្រាក់ គឺត្រូវចាយឱ្យមានប្រយោជន៍ជាទីបំផុត ។ ព្យាយាមយកឈ្នះចិត្តអាក្រក់របស់ខ្លួនឯង កុំខ្ជះខ្ជាយខ្ជោកខ្ជាកឱ្យសោះ ។

សូមកូនម៉ែ ខំប្រឹងរៀនឱ្យបានឡើងថ្នាក់រាល់ឆ្នាំ ព្រោះការរៀនធ្លាក់ត្រូវត្រួតថ្នាក់នោះ គឺជាការខូចពេលវេលា ខូចកម្លាំងចិត្តនិងអស់ប្រាក់ថែមផ្ទួនទៅទៀតផង ។

អ្នកប្រាជ្ញបានពោលថា « មនុស្សល្ងង់ កាលបើមានពេល ក៏រីករាយភ្លើតភ្លើនទៅក្នុងការរកអាហារឆ្ងាញ់ៗមកដាក់មាត់ ដាក់ពោះ ចំណែកមនុស្សឆ្លាត កាលបើមានពេលហើយ ក៏រីករាយក្នុងការរកអាហារមកដាក់ខួរក្បាល នាំឱ្យមានបញ្ញា ដូច្នេះ កូនម៉ែត្រូវរៀនច្រើន អានច្រើន ស្តាប់ច្រើន ហើយសំខាន់បំផុត ត្រូវមានមិត្តល្អ » ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

## អាភរណៈដ៏ប្រសើរ

ម៉ែឪដែលមានកូនចេះស្គាល់ប្រមាណខ្លួន ចេះដឹងចំពោះឋានៈក្នុងគ្រួសាររបស់ខ្លួន ទើបជាអ្នកមានជោគល្អ បីដូចជាបានទទួលពរអំពីព្រះឥន្ទ ។

កូនជាទីស្រឡាញ់របស់ម៉ែ កូនពិតជាបានឃើញហើយ ចំពោះប្រុសស្រីខ្លះ តែងខ្លួនឆើតឆាយ តាក់តែងកាយដោយសម្លៀកបំពាក់ដែលមានតម្លៃខ្ពស់បំផុត ព្រមដោយអលង្ការ ប៉ុន្តែ មិនចេះរៀបចំខ្លួនឱ្យជាទីស្រឡាញ់ចូលចិត្តឡើយ ។ ប្រុសស្រីរបៀបនេះ មិនអាចប្រៀបបាននឹងអ្នកដែលតែងខ្លួនគ្រាន់តែឱ្យបានសមរម្យប៉ុណ្ណោះ ប៉ុន្តែរៀបរយត្រឹមត្រូវ សុភាពរាបសា ច្រើនទៅដោយមេត្តាករុណានោះឡើយ ។

កែវភ្នែកស្រទន់ កិរិយាសុភាព វាចាពីរោះស្មោះត្រង់ត្រឹមត្រូវនិងចិត្តពេញទៅដោយព្រហ្មវិហារ នោះគឺជាស្នេហ៍ទាញស្រូបមនុស្សទាំងឡាយ ឱ្យស្រឡាញ់ ឱ្យគោរព



កោតក្រែង បីដូចជាជ្រោះជើងភ្នំដែលជាទីហូរធ្លាក់ចុះមកនៃទឹកដូច្នោះឯង ។

ចូរកូនចាំពាក្យម៉ែទុកចុះ ទោះបីកូនក្រីក្រទ្រព្យសម្បត្តិក៏ដោយ តែកូនមិនត្រូវក្រសេចក្តីល្អឡើយ ថ្វីត្បិតតែកូនមិនមាននូវឋានៈខ្ពង់ខ្ពស់ក្នុងសង្គម តែសូមឱ្យកូនអណ្តែតខ្លួនក្នុងពន្លឺរស្មីនៃសតិបញ្ញា ។

ក្នុងការរៀន ការតម្កល់ខ្លួន ឬការអ្វីៗទៀតក៏ដោយ ម៉ែសូមដាស់តឿនកូនថា ចូរកុំប្រហែស «ស្វាក៏ចេះប្រយ័ត្នខ្លួនកុំឱ្យធ្លាក់ពីលើចុងឈើដែរ» មនុស្សយើងទោះបីជំនាញប៉ុនណា ឆ្លៀវឆ្លាតអង់អាចប៉ុនណាក៏ដោយ កាលណាបើប្រមាទធ្វេសប្រហែសហើយ ក៏រមែងភ្លាត់ប្លាតធ្លាក់ខ្លួនដូចជាមនុស្សល្ងង់ខ្លៅអឺចឹងឯង ។

ក្នុងការរៀបចំទុកដាក់ខ្លួនជាមួយមិត្តភ័ក្តិ កុំឱ្យខ្ពស់ពេកនាំឱ្យគេស្អប់ តែបើដាក់ខ្លួនទាបជាងគេពេកនាំឱ្យគេមើលងាយ ដូច្នេះ ត្រូវឱ្យល្មមៗ ។ ឯចំណែកជាមួយគ្រូអាចារ្យនោះ កូនត្រូវទន់ភ្លន់ គោរពឱនលំទោន ដូចពាក្យ

Document Produced by deskPDF Unregistered :: http://www.docudesk.com

លោកពោលទុកថា :

« ឈ្នះអ្នកស័ក្តិខ្ពស់ដោយការឱនលំទោន
ឈ្នះអ្នកទាបទន់ខ្សោយដោយការសង្គ្រោះ
ឈ្នះអ្នកស្មើគ្នាដោយការព្យាយាម » ។

ចំណែកឯការរៀបចំខ្លួនជាមួយភេទផ្ទុយគ្នា ម៉ែសូមបញ្ជាក់ប្រាប់ដល់កូនស្រីម៉ែថា មនុស្សប្រុសខ្លាចមនុស្សស្រីណាដែលរៀបចំនូវឥរិយាបថល្អ មិនតម្កើងខ្លួនវាយឫក ហើយក៏មិនបណ្ដោយខ្លួនដែរ មានអាកប្បកិរិយាល្អ រៀបរយរាបសា មិននិយាយលេងរហូតដល់ហួសវិស័យស្រី កាលបើដូចនេះ មនុស្សប្រុសរមែងក្រែងចិត្ត និងនិយាយលើកតម្កើង ។

សូមកូនម៉ែរក្សានូវគុណតម្លៃរបស់មនុស្ស ឱ្យបានឋិតនៅមាំមួនក្នុងខ្លួន សូមកូនកុំជាមនុស្សអស់តម្លៃឱ្យសោះ គុណតម្លៃមនុស្សគឺជាសិរីសួស្តី និងជាអាភរណៈដ៏ប្រសើរក្នុងជីវិត ។



# កូនម៉ែត្រូវហ្វឹកហាត់ឱ្យមានឧបនិស្ស័យល្អ

មនុស្សយើងដែលនឹងបានល្អនោះ ក្រៅអំពីត្រូវមានការសិក្សារៀនសូត្រហើយ គឺត្រូវហ្វឹកហាត់អប់រំដើម្បីឱ្យមាននូវឧបនិស្ស័យល្អទៀតផង នេះជាប្រការសំខាន់។

ចំណុចផ្ដើមនៃការហ្វឹកហាត់សិក្សាអប់រំដែលជាទីសំខាន់បំផុត គឺក្រុមគ្រួសារក្នុងផ្ទះ ។ គ្រួសារដែលនៅក្នុងសភាពរៀបរយល្អនោះ តិចណាស់ដែលក្មេងទៅជាខិលខូចឡេះឡោះ នេះព្រោះការសេពគប់បានសមប្រពៃ ។

លុះដល់កូនធំឡើង កូនត្រូវខំព្យាយាមសេពគប់សមាគមជាមួយមនុស្សល្អ ដើម្បីបានចម្លងនូវលក្ខណៈល្អផ្សេងៗ ការសេពគប់មនុស្សល្អ រមែងជាគុណប្រយោជន៍ដល់កូនរហូតក្នុងជីវិត ។

មនុស្សល្អ កាលបើកូនចូលទៅជិតហើយ ធ្វើឱ្យកូនដឹងខ្លួនថា ចង់បានឱ្យខ្លួនទៅជាមនុស្សល្អដែរ ។ មនុស្សស្លូតក៏ដូចគ្នា កាលបើកូនចូលទៅជិតហើយ បានស្ដាប់នូវ

Document Produced by deskPDF Unregistered :: http://www.docudesk.com

ពាក្យសម្ដីអ្វីខ្លះនោះ រមែងធ្វើឱ្យកូនដឹងខ្លួនឯងថា មានសេចក្ដីស្ងប់ ហើយចង់ឱ្យខ្លួនបានទៅជាមនុស្សស្ងប់ទៀតផង ដូច្នេះការសេពគប់ជាចំណុចសំខាន់បំផុត ។

ក្រៅអំពីអាស្រ័យអ្នកដទៃដើម្បីជួយហ្វឹកហាត់អប់រំហើយ ការហ្វឹកហាត់ខ្លួនឯងជាកិច្ចចាំបាច់បំផុត ដោយចំពោះ គឺហ្វឹកហាត់ខ្លួនឯងក្នុងការយកឈ្នះអំណាចនៃធម៌ថោកទាប អ្នកដែលហ្វឹកហាត់ទូន្មានខ្លួនបាន គឺជាមនុស្សប្រសើរ ហើយឈ្មោះថា បាននូវទីពឹងដែលគេបានដោយកម្រ ។

ហ្វឹកហាត់អប់រំខ្លួនឱ្យទៅជាមនុស្សមានព្យាយាម។ មនុស្សដែលមាននូវសេចក្ដីប្រឹងប្រែងព្យាយាម សូម្បីមានជីវិតរស់នៅត្រឹមតែមួយថ្ងៃ ក៏ប្រសើរជាងមនុស្សខ្ជិលដែលរស់នៅអស់រយនៃឆ្នាំ ។

ចូរកូនម៉ែប្រើពេលវេលាឱ្យជាប្រយោជន៍ ព្រោះពេលវេលាដែលកន្លងទៅហើយ មិនត្រឡប់មកវិញឡើយ អស់ទៅហើយក៏ជាការអស់ទៅហើយហ្នឹងឯង ។ តម្លៃនៃ



ពេលវេលានៅត្រង់ដែលកូនប្រើវាឱ្យជាប្រយោជន៍ មនុស្សដែលមិនធ្វើការងារជារបស់មនុស្ស ជីវិតក៏អស់ទៅទទេ ចំណែកមនុស្សដែលមានការព្យាយាម រមែងកាន់យកនូវប្រយោជន៍ សន្សំទុកនូវប្រយោជន៍ រហូតដល់បានសម្រេចនូវប្រយោជន៍ធំ គឺការរួចផុតពីសេចក្ដីទុក្ខ។

មនុស្សដែលធ្វើនូវការងារច្រើន មិនអាចបានជាមនុស្សសំខាន់គ្រប់គ្នាឡើយ ប៉ុន្តែ មនុស្សសំខាន់នៅត្រង់ធ្វើការងារដោយសេចក្ដីព្យាយាមជានិច្ច ។ តម្លៃរបស់មនុស្សវាស់គ្នាត្រង់ផលនៃការងារនិងសេចក្ដីល្អប្រចាំខ្លួន។

កូនម៉ែត្រូវខំសន្សំឧបនិស្ស័យល្អ ។ ឧបនិស្ស័យគឺអ្វីដែលធ្វើឱ្យជាទម្លាប់ ឧបនិស្ស័យល្អគឺជាភូមិឋាននៃការចម្រើនគុណធម៌គ្រប់យ៉ាង ប្រៀបបីដូចជាដីចំការដែលល្អដូច្នោះឯង ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

## បើកូនស្រីម៉ែធ្វើល្អហើយឱ្យគេថាចុះ

កាលកូនស្រីនៅតូចម៉ែជាអ្នករៀបចំតែងខ្លួនឱ្យកូនស្លៀកពាក់យ៉ាងណា ស្ពាយកាបូបទៅសាលាយ៉ាងម៉េចទើបសម ម៉ែរៀបចំឱ្យកូនទាំងអស់ ។ ម៉ែតែងតែតាមគយគន់ដំណើរកូនដោយការពេញចិត្ត ។

លុះដល់ពេលកូនស្រីធំឡើង អ្វីៗដែលជាធម្មជាតិសម្រាប់ខ្លួនកូន ម៉ែក៏បានប្រាប់ពន្យល់ឱ្យកូនបានដឹងទាំង-អស់ ។ ឥឡូវម៉ែសូមពន្យល់កូនស្រីអំពីបញ្ហាមួយដែលកូនចេះតែខ្លាច «ពាក្យគេថា » សូមកូនចាំស្តាប់ ហើយពិចារណាឱ្យល្អ ដើម្បីដោះស្រាយនូវបញ្ហាមួយនេះឱ្យបានជ្រះស្រឡះ ។

កូនខ្លាច «គេថា» ពាក្យថា «គេ » សំដៅដល់មនុស្សទាំងឡាយដទៃលើផែនដីក្រៅពីកូន ។ សូម្បីកូនប្រាកដនៅក្នុងចិត្តហើយថា នេះជាអំពើល្អត្រឹមត្រូវ នៅតែ



កូនមិនក្លាហានដើម្បីនឹងប្រព្រឹត្តធ្វើ ព្រោះខ្លាច «គេថា» រឿង «គេថា» នេះ វាក្លាយទៅជារបស់ដែលគួរខ្លាចជាទីបំផុតក្នុងលោកនេះទៅហើយ ។

សម្រាប់កូនស្រី បើមានសេចក្តីប្រកាន់យ៉ាងនេះក៏មិនអាចធ្វើអ្វីបានឡើយ ព្រោះ«គេ»មានច្រើនណាស់។ ម្នាក់ៗមានការគិតឃើញរៀងៗខ្លួន ត្រូវគ្នាខ្លះមិនត្រូវគ្នាខ្លះ កាលកូនស្រីធ្វើនូវអ្វីមួយ អ្នកខ្លះគេថាល្អ អ្នកខ្លះទៀតគេថាមិនល្អ ឬអាចគេថាអាក្រក់តែម្តង ដូច្នេះ កូនស្រីត្រូវតែសម្រេចថា អាត្មាអញគប្បីធ្វើនូវអ្វីដែលសមគួរដល់ខ្លួនឯងផង ដែលមិនខុសច្បាប់ផង មិនខុសសីលធម៌ផង មិនបៀតបៀនឱ្យអ្នកណាក្តៅក្រហាយផង ហើយអាត្មាអញសប្បាយចិត្តនឹងធ្វើផង ដូច្នេះអាត្មាអញត្រូវតែធ្វើដោយមិនមានកង្វល់នឹងពាក្យគេថាអ្វីឡើយ ។ ប៉ុន្តែម៉ែសូមរំលឹកកូនស្រី ចូរកូនកុំភ្លេចផ្ទៀងផ្ទាត់នូវកិច្ចការងារនោះ ឱ្យជាការងារល្អត្រឹមត្រូវពិតប្រាកដផង ។

ការរិះគន់និន្ទាគ្នាន់ក្នាញ់ ជារបស់ធម្មតាក្នុងលោក

អ្នកខ្លះប្រើពេលវេលាទំនេរទៅក្នុងការអានសៀវភៅ អ្នកខ្លះរីករាយនៅក្នុងការលេងកីឡា... អ្នកខ្លះជ្រើសរើសយកការនិន្ទារិះគន់គ្នាន់ក្នាញ់ចំពោះអ្នកដទៃ មកជាការងារធំដុំក្នុងជីវិត ។ អ្នកដែលសម្លឹងទោសគេដោយអកុសល-ចិត្ត និយមនិយាយរឿងអាក្រក់របស់គេ គឺជាអ្នកមិនមានសេចក្ដីចម្រើនក្នុងជីវិតឡើយ ព្រោះគិតតែនាំយករឿងអាក្រក់មកដាក់ក្នុងខ្លួនឯងរាល់ថ្ងៃ បីដូចជាធុងសំរាមប្រឡាក់ប្រឡូសទៅដោយរបស់ស្មោកគ្រោក ជាការសាងនូវគ្រឿងដែលរារាំងសេចក្ដីចម្រើនឱ្យដល់ខ្លួនឯង ជាអ្នកបញ្ឆោតខ្លួនឯង ឱ្យរីករាយដោយសេចក្ដីវង្វេងក្នុងផ្សែងនៃសេចក្ដីអាក្រក់ ។

មនុស្សយើងចង់គេចអំពីអ្វីផ្សេងៗ ក៏អាចនឹងគេចបាន ប៉ុន្តែយើងមិនអាចគេចអំពីកម្មពៀរ និងគេចអំពីខ្លួនឯងបានឡើយ លុះត្រាតែចូលនិព្វានទើបអាចគេចផុតបាន ដូច្នេះ មនុស្សដែលល្អគេរមែងទទួលយកសភាពពិតរបស់ខ្លួន មិនមែនចេះតែបញ្ឆោតខ្លួនឯងដោយសេចក្ដីវង្វេង



រឿយៗទៅនោះឡើយ ។ ការព្រមទទួលយកនូវសេចក្ដីពិតរមែងធ្វើឱ្យភាពលំបាកក្នុងចិត្តបានធូរស្រាលពិតប្រាកដ ។

កូនស្រីម៉ែត្រូវរៀនទទួលយកការពិតរបស់ជីវិត កុំចេះតែញាប់ញ័រទៅតាមពាក្យគេថា ។ ត្រូវរៀនឱ្យយល់ពីហេតុផលរបស់ធម្មជាតិ ចាប់យកការពិតនៃជីវិតមកសិក្សារហូតបានយល់ច្បាស់ហើយរស់នៅដោយសេចក្ដីស្ងប់ចិត្ត។

ចូរកូនចាំទុកថា «មិនមានការរស់នៅជាមួយអ្វីឱ្យបានសុខ ស្មើនឹងការរស់នៅជាមួយសេចក្ដីស្ងប់ឡើយ »។

ព្រះចន្ទនិងថ្ងៃឥតមានដឹងអ្វី តែត្រូវប្រុសស្រីនិន្ទាសរសើរ
ពពករសាត់ដូចមានស្លាបហើរ ភ្លៀងខ្យល់ដេកដើរគេថាទាំងអស់។
បួសជាព្រះសង្ឃនៅគេរិះគន់ ធ្វើចោរលួចប្លន់គេទាន់ដាក់ខ្នោះ
ត្រាស់ជាព្រះពុទ្ធនៅគេមិនស្មោះ ធម៌ល្អឥតខ្ចោះគង់មានគេស្អប់។
សរសើរនិន្ទាមានពីបុរាណ កាន់យកមិនបានតាមពាក្យទាស់គាប់
បើកូនតាមប្រាជ្ញកូននឹងមានភ័ព្វ ត្រូវមួយខុសដប់កុំយកខាងច្រើន។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

# កូនស្រីម៉ែត្រូវធ្វើថ្ងៃនេះឱ្យល្អបំផុត

កូនស្រីម៉ែនឹកគិតដល់រឿងអនាគត រឿងរៀបការមានគ្រួសារ រឿងឋានៈក្នុងការរស់នៅ រឿងទាំងអស់នេះសុទ្ធតែជារឿងដែលនៅឆ្ងាយ ។ កូនស្រីគួរបញ្ឈប់ការគិតខ្វល់ខ្វាយក្នុងរឿងនេះ ព្រោះគិតទៅក៏ឥតប្រយោជន៍ដែរ កូនស្រីម៉ែគិតតែខំរៀនសិនទៅ ។

ដូចដែលម៉ែធ្លាប់ប្រាប់ដល់កូនហើយថា« ធ្វើថ្ងៃនេះឱ្យល្អជាទីបំផុតទៅ អនាគតវានឹងរៀបចំដោយខ្លួនឯង »។ ថ្ងៃនេះ ម៉ែនឹងអធិប្បាយនូវសេចក្ដីនេះ ចូរកូនយកចិត្តទុកដាក់ស្ដាប់ឱ្យល្អចុះ ។

សេចក្ដីសម្រេចនៃការសាងឋានៈក្នុងអនាគតនោះ វាឋិតនៅត្រង់ការសាងថ្ងៃនេះឯង ក្នុងមួយថ្ងៃៗកូនត្រូវសាងឱ្យល្អ តាមកម្លាំងដែលកូនអាច ឬតាមសមត្ថភាពដែលកូនមាន ។



មនុស្សរមែងផ្សេងគ្នាមកអំពីកំណើត គឺម្នាក់ៗរៀងៗខ្លួន ហើយមានអង្គប្រកបច្រើនយ៉ាងទៀតដែលធ្វើឱ្យឋានៈនៃការរស់នៅរបស់មនុស្ស ផ្សេងៗអំពីគ្នាកាន់តែច្រើនឡើង ដែលសំខាន់គឺអង្គប្រកបផ្ទាល់ខ្លួនឯង និងអង្គប្រកបផ្នែកខាងសង្គម ។

អង្គប្រកបផ្ទាល់ខ្លួនឯងបានដល់ ឱកាស ស្ថានទីអ្នកណែនាំ ការប្រព្រឹត្តផ្ទាល់ខ្លួន និងបុណ្យបាបដែលខ្លួនធ្វើមកមិនស្មើគ្នាជាដើម ។

អង្គប្រកបផ្នែកខាងសង្គមបានដល់សភាពនៃសង្គមដែលខ្លួនត្រូវបានទទួលការគ្រប់គ្រង ការជួយសង្គ្រោះអំពីសង្គម និងដំណើរប្រព្រឹត្តទៅនៃការប្រកបអាជីពក្នុងសង្គមជាដើម ។

យ៉ាងណាក៏ដោយ មនុស្សយើងមានចំនួនច្រើនណាស់ ដែលសម្លឹងសំដៅទៅរកតែភាពមាំទាំនៃទ្រព្យសម្បត្តិ ឬក៏តំណែងនៃការងារខ្ពង់ខ្ពស់ប៉ុណ្ណោះ ថាជាសេចក្ដីសម្រេចនៃជីវិត ពោលគឺយកនូវរបស់ទាំងនេះមក

ជាគ្រឿងវាស់វែង ។

មនុស្សក្នុងលោកយើងនេះ វិលវល់នៅតែក្នុងការស្វែងរក ប្រាក់ កិត្តិយស និងមុខតំណែងប៉ុណ្ណោះឯង ព្រោះសង្គមបានសន្មតឱ្យថាជាមុខមាត់ និងជារបស់ដែលសង្គមលើកតម្កើងឱ្យតម្លៃ ប៉ុន្តែ យ៉ាងដូចម្ដេចដែរ ក្នុងលោកយើង ឬក៏ក្នុងបុគ្គលម្នាក់ៗនោះ មាននូវសេចក្ដីសុខស្ងប់ដែរឬទេ ?

ការនិយមឱ្យតម្លៃ ទៅលើអ្វីក្នុងលោកយើងទាំងមូលនេះ ខុសឬត្រូវយ៉ាងណា តាមតែកូនពិចារណាមើលចុះ ។ អវិជ្ជាគឺសេចក្ដីងងឹតរបស់ចិត្ត ធ្វើមិនឱ្យមនុស្សយើងមើលឃើញ នូវគុណតម្លៃពិតប្រាកដរបស់ជីវិតឡើយ វាធ្វើឱ្យយើងស្រវាចាប់យកនូវរបស់ដែលនាំមកនូវក្រវល់ក្រវាយរហូតរឿយៗ ជាការដើរបញ្ច្រាសអំពីសេចក្ដីសុខស្ងប់ ប្រៀបដូចជាអ្នកដើរបែរខ្នង ឱ្យពន្លឺភ្លឺស្វាង ហើយឈមមុខទៅរកភាពងងឹតដូច្នោះឯង ឬក៏ដូចអ្នករែកដុំថ្មធំដើរទៅក្នុងផ្លូវនៃជីវិត មាត់ក៏ចេះតែស្រែកថា« ធ្ងន់ ធ្ងន់ »



មានអ្នកបំណងល្អស្រែកប្រាប់ទៅថា «ដាក់ដុំថ្មចុះ ហើយដើរទៅ» អ្នករែកដុំថ្មនោះបែរមកមើលអ្នកដែលដាស់តឿនបន្តិចរាងបែបសង្ស័យ រួចហើយក៏រែកនូវដុំថ្មដ៏ធំនោះដើរបន្តទៅទៀតព្រមដោយការពោលថា « ធ្ងន់ ធ្ងន់ » ។

សេចក្ដីសម្រេចនៅក្នុងជីវិតរបស់មនុស្សនោះមានច្រើនផ្នែក មិនចាំបាច់ត្រូវតែដូចគ្នានោះទេ ដូច្នេះកូនស្រីម៉ែ មិនចាំបាច់ត្រូវមានសេចក្ដីសម្រេចក្នុងជីវិតទៅតាមតែផ្លូវមួយដូចជាអ្នកដទៃនោះឡើយ ពោលគឺមិនគួរស្វែងរកនូវសេចក្ដីសម្រេចខាងផ្នែកវត្ថុតែម្យ៉ាងនោះទេ ។ **ផ្លូវដែលត្រូវ គួរស្វែងរកសេចក្ដីសម្រេច ខាងផ្នែកផ្លូវចិត្ត ឱ្យច្រើនជាងខាងផ្នែកវត្ថុ** ។

ម៉ែមិនមែនចង់ពោលបដិសេធនូវទ្រព្យសម្បត្តិ កិត្តិយស និងមុខតំណែងនោះទេ តែម៉ែចង់ដាស់តឿនកូនកុំឱ្យកូនស្រីចង់ស្រវាយកតែផ្នែកម្យ៉ាងហ្នឹងនោះ ត្រូវឱ្យឃើញសេចក្ដីសំខាន់ផ្នែកខាងផ្លូវចិត្តផង គឺចិត្តស្អាតនិងសេចក្ដីសុខស្ងប់ ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

សេចក្ដីសម្រេចខាងផ្នែកវត្ថុ ជារបស់ក្ដៅលោយ-ឡំដោយទុក្ខនិងកង្វល់ផ្សេងៗ ចំណែកសេចក្ដីសម្រេចខាងផ្លូវចិត្តជារបស់ស្ងប់ត្រជាក់ ។

ពិតណាស់ យើងត្រូវមានការងារធ្វើទៅតាមមុខនាទី ដើម្បីបាននូវវត្ថុសម្រាប់ចិញ្ចឹមរាងកាយ ព្រមទាំងការងារបម្រើប្រទេសជាតិ ហើយនេះក៏ជាកិត្តិយសផងដែរ ប៉ុន្តែ យើងមិនត្រូវភ្លេចស្វែងរក និងសន្សំនូវគ្រឿងសម្រាប់ចិញ្ចឹមដួងចិត្តរបស់យើងផងឡើយ ពោលគឺគុណ-ធម៌ដែលជាសេចក្ដីល្អផ្សេងៗ ។

មនុស្សស្រីយើងដោយច្រើន ចូលចិត្តប្រើពេលវេលាឱ្យអស់ទៅដោយការតែងកាយ ស្វែងរកសំពត់អាវតាមបែបផ្សេងៗមកស្លៀកពាក់ បង្អួតគ្នា និងប្រលងគ្នាថាតើអ្នកណាតែងបានស្អាតជាងអ្នកណា ។

អ្នកដទៃយ៉ាងម៉េចក៏ដោយចុះ ប៉ុន្តែកូនស្រីម៉ែគួរតែប្រើពេលវេលាក្នុងការតែងចិត្តឱ្យបានល្អស្អាត ស្វែងរកវិជ្ជា និងអប់រំសន្សំគុណធម៌ឱ្យជាគ្រឿងប្រដាប់ចិត្ត ។



រាងកាយនេះឯងទោះជាតែងយ៉ាងណា ក៏វានៅតែមានគ្រឿងបដិកូលស្មោកគ្រោក និងមានក្លិនស្អុយដដែលជារៀងរាល់ថ្ងៃ ។ អាភរណៈសំពត់អាវស្រស់ស្អាតមានតម្លៃប៉ុនណាក៏ដោយ លុះដល់យកមកស្លៀកដណ្ដប់ហើយក៏ក្លាយទៅជាស្មោកគ្រោក មានក្លិនស្អុយទៅផងដែរ ជាការបញ្ជាក់យ៉ាងច្បាស់ថា មិនមានឧបាយយកឈ្នះគ្រឿងបដិកូលរបស់រូបកាយបានឡើយ ។

ចំណែកដួងវិញ្ញាណ ឬដួងចិត្តវិញនោះ កាលដែលជម្រះបានស្អាតម្ដងហើយ ក៏ជាការបានសម្រេចនូវភារកិច្ចដោយពិត រឹងរឹតតែស្អាតរឹងរឹតតែភ្លឺស្វាង រឹងរឹតតែភ្លឺស្វាងរឹងរឹតតែស្ងប់ បាននូវសេចក្ដីស្ងប់ប៉ុនណា ក៏ជាការបានជួបនូវភាពជាសុខ និងគុណតម្លៃរបស់ជីវិតតាមសេចក្ដីពិតប៉ុណ្ណោះដែរ ។

ក្នុងផ្លូវលោក បានអប់រំមនុស្សតែអំពីសិល្បៈនៃការស្វែងរក ប្រកួតប្រជែងគ្នា ថាតើអ្នកណារកបានច្រើនជាងអ្នកណា មិនបានអប់រំឱ្យរំលត់នូវសេចក្ដីប្រាថ្នា ក្នុង

របស់ដែលមិនចាំបាច់នោះខ្លះឡើយ កាលបើដូច្នេះហើយ តើប៉ុនណាទើបជាការគ្រប់គ្រាន់ តើពេលណាទើបបានរួចផុតពីការអន្ទះសាប្រាថ្នាចង់បាន ដែលវាមិនមានព្រំដែនកំណត់នោះ ។

តាមការពិត របស់ដែលចាំបាច់ដល់ជីវិតពិតៗនោះមិនមែនច្រើនប៉ុន្មានឡើយ ប៉ុន្តែការប្រកួតប្រជែងគ្នាក្នុងពួកមនុស្សយើងវាជារឿងមួយដោយឡែក ប្រៀបបីដូចជាយកប្រេងមកចាក់ស្រោចលើអណ្ដាតភ្លើងអ៊ីចឹងឯង ។ ភ្លើងសេចក្ដីប្រាថ្នា កាលបើត្រូវបន្ថែមគ្រឿងសម្រាប់ឱ្យឆេះហើយ ក៏រមែងឆេះសន្ធោសន្ធៅរហូតដល់ថ្នាក់លែងពន្លត់កើត ព្រោះហេតុដូច្នេះហើយ ទើបមនុស្សយើងមានកម្ដៅក្ដៅអន្ទះអន្ទែង ដែលគួរឱ្យនឹកបារម្ភដល់សេចក្ដីអន្តរាយផ្សេងៗ ។

បើយើងកំណត់សេចក្ដីត្រូវការរបស់យើង ឱ្យនៅក្នុងព្រំដែនល្មមប្រមាណ ម៉ោងពេលនៃការស្វែងរកក៏នឹងកាត់បន្ថយបាន ពេលដែលនៅសល់ក៏នឹងត្រូវបានមកជា



ពេលនៃសេចក្ដីសុខស្ងប់ ពោលគឺស្ងប់នូវតណ្ហាហ្នឹងឯង ។

មនុស្សយើង ដែលស្វែងរកទ្រព្យសម្បត្តិទុកសន្ទឹកសន្ធាប់ លើសលប់ពីការចាំបាច់នោះ តើយកធ្វើអ្វីបានខ្លះ ជីវិតរបស់យើងខ្លីណាស់ មួយថ្ងៃៗអស់ទៅជារឿយៗ រស់នៅមិនបានប៉ុន្មានផងក៏ចាស់ ហើយក៏ត្រៀមខ្លួនចាំស្លាប់ **ការសន្សំទ្រព្យទុកច្រើនលើសពីចាំបាច់ ធ្វើឱ្យខូចពេលវេលាទៅទទេៗ** មនុស្សខ្លះមានតែវេចស្ពាយយកបាបកម្មដ៏ច្រើនទៅជាមួយផង ចំណែកទ្រព្យសម្បត្តិត្រូវបានចាកចោលទុកឱ្យនៅក្នុងលោកនេះឯង ។

កូនស្រីធ្លាប់បានអានប្រវត្តិសាស្ត្រក្នុងលោក ក៏គង់បានដឹងហើយ ថាតើទ្រព្យសម្បត្តិនិងផែនដីនេះ អ្នកណាយកទៅបានខ្លះ ដូចជាអ្នកដែលបានច្បាំងឈ្នះ ហើយគ្រប់គ្រងបានច្រើននគរនោះ ។

បើមានអ្នកណាគេលើកយកផ្លូវថ្នល់ទាំងអស់មកឱ្យកូន កូនក៏គង់តែប្រើថ្នល់នោះបានមិនច្រើនជាងដែលកូនប្រើសព្វថ្ងៃនេះឡើយ ប៉ុន្តែសេចក្ដីធ្ងន់និងស្រាលក្នុងចិត្តវា





Document Produced by deskPDF Unregistered :: http://www.docudesk.com

រមែងខុសគ្នាច្រើន ពេលនេះការប្រើប្រាស់ផ្លូវថ្នល់ដោយការធូរស្រាលក្នុងចិត្ត គឺគ្រាន់តែអាស្រ័យការប្រើប្រាស់ដោយមិនបានប្រកាន់ថា ជារបស់កូនម្នាក់ឯងឡើយ ប៉ុន្តែបើកូនជាម្ចាស់តែម្នាក់ឯងវិញនោះ ភារកិច្ចផ្សេងៗដែលទាក់ទងនឹងផ្លូវថ្នល់ទាំងអស់ ក៏មកជាមួយនឹងផ្លូវថ្នល់នោះផងដែរ ។ ចូរកូនបានដឹងចុះថា ការមានបាននូវអ្វីមួយនោះ វារមែងមានបានមកជាមួយនឹងការថែទាំរក្សា និងកង្វល់ផ្សេងៗ ។ របស់កង្វល់ទាំងនោះវានឹងប្លន់យកនូវពេលវេលារបស់កូនទៅទាំងអស់ រហូតដល់កូនមិនមានពេលទំនេរសម្រាប់ខ្លួនកូនឯងខ្លះឡើយ ។

ម៉ែនិយាយមកនេះ ដើម្បីឱ្យកូនស្រីបានធូរកង្វល់នៅក្នុងរឿងសាងឋានៈនាអនាគត។ ពេលនេះយើងក៏មាននូវទ្រព្យល្មមកូនរៀនបានហើយ ជំនិះក៏មាន ផ្លូវថ្នល់ក៏មានសាលារៀនក៏មាន ទីធ្លាក៏មាន វត្តអារាមក៏មាន សូម្បីមិនជារបស់យើងដាច់មុខ តែយើងក៏មានសិទ្ធិប្រើបាន ល្មមដែលយើងត្រូវការ គ្រាន់តែត្រូវចំណាយប្រាក់ខ្លះដូចជា



តម្លៃក្នុងយានជំនិះជាដើម ។

ប្រសិនបើកូនស្រីម៉ែ ជាម្ចាស់នៃទឹកបឹងទន្លេទាំងអស់ក្នុងលោក កូនផឹកវាក្នុងមួយថ្ងៃបានត្រឹម ៦-៧ កែវប៉ុណ្ណោះ បើជាម្ចាស់នៃសំពត់ខោអាវទាំងអស់ក្នុងហាងឬក្នុងផ្សារ កូនប្រើបានត្រឹម ២-៣ សម្រាប់ប៉ុណ្ណោះក្នុងមួយថ្ងៃ ហើយវាក៏មិនមែនធ្វើឱ្យកូនទៅជាទេវតាបានដែរ គង់នៅតែជាមនុស្សដែលមានការស្រេកឃ្លាន ឈឺបន្ទោបង់ឧច្ចារៈ បស្សាវៈ ហើយត្រូវចាស់ ឈឺ និងស្លាប់ក្នុងទីបំផុត ដូច្នេះការល្មោភលោភលន់ក្នុងទ្រព្យសម្បត្តិ ទើបជាការល្ងង់ខ្លៅម្យ៉ាងរបស់មនុស្សយើង វាជាដុំពពកអ័ព្ទបិទបាំងនូវគុណតម្លៃដែលពិតប្រាកដនៃជីវិតមនុស្ស ។

ចំណែករឿងរៀបការនិងរឿងគ្រួសារនោះ កូនស្រីមិនចាំបាច់គិតអ្វីពេលនេះទេ ខំរៀនឱ្យបានសម្រេចសិនទៅ ពេលវេលានៅច្រើនទៀតណាស់ដែលសម្រាប់គិតគូរនោះ ប៉ុន្តែ ម៉ែសូមផ្ញើគំនិតរបស់ម៉ែក្នុងពេលនេះទុកឱ្យកូនសិនថា កូនស្រីប្រាថ្នាខ្ពស់ក៏បាន តែកូនស្រីត្រូវធ្វើខ្លួន





Document Produced by deskPDF Unregistered :: http://www.docudesk.com

ឱ្យខ្ពស់ផង បើកូនស្រីទាបទេ តែប្រាថ្នាខ្ពស់នោះ គឺកូនស្រីមិនផុតពីធ្លាក់ចុះមកនៅក្នុងដៃរបស់មនុស្សទាបជាមិនខាន ហើយម្យ៉ាងទៀត រឿងគូគ្រងនោះមិនចាំបាច់ស្វែងរកឡើយ ដល់ពេលវេលាសមគួរហើយ ក៏រមែងមកដល់ជាធម្មតា អ្នកណាចិត្តក្តៅទៅតាមតែអំណាចនៃកិលេស អ្នកនោះនឹងស្តាយក្រោយ ជាមួយគ្នានឹងការបាត់បង់នូវកិត្តិយស ។ ម៉ែសង្ឃឹមថាកូនស្រីម៉ែនឹងរក្សានូវកិត្តិយសរបស់ខ្លួន កិត្តិយសគ្រួសារ ព្រមទាំងកិត្តិយសរបស់ប្រទេសជាតិយើងផង ។

ការរៀនបានល្អ និងការប្រព្រឹត្តល្អរបស់កូន ចាត់ជាពរដ៏ប្រសើរដែលកូនឱ្យដល់ឪពុករបស់កូន និងម៉ែ ព្រមទាំងក្រុមគ្រួសារ ឪពុករបស់កូន និងម៉ែចង់ទទួលនូវពរនេះអំពីកូនច្រើនជាងពរដោយវាចាពីរោះទៅទៀត ។ សេចក្តីល្អរបស់កូនដែលចេញពីមាត់គ្រូ និងមាត់អ្នកដទៃទៀតនោះ ធ្វើឱ្យឪពុកម្តាយ សប្បាយរីករាយចិត្ត វាជារបស់ទិព្វម្យ៉ាងត្រង់ដែលបានឮដំណឹងថា កូនស្រីម៉ែជា



មនុស្សល្អ តាំងចិត្តរៀនសូត្រពិតប្រាកដ វាពិតជាអាហារទិព្វសម្រាប់ឪពុកម្តាយមែន ព្រោះឪពុកម្តាយនឹកដល់ពេលណា ក៏ធ្វើឱ្យឆ្អែតទៅដោយបីតិក្នុងពេលនោះឯងគ្រប់គ្រាគ្រប់វេលា ។

## ពាក្យមេទាំងអស់ប្រដូចនឹងម៉ែ

ភ្នំព្រះសុមេរ៍គឺជាមេភ្នំ ធំក្រៃលែងធំទ្រង់ត្រៃត្រិង្សឋាន
តែគង់នៅតូចជាងម៉ែកល្យាណ ព្រោះម៉ែទ្រឋានព្រះព្រហ្មមុខបួន។
ម៉ែពិតជាធំនៅក្នុងលោកា មេទ័ពខ្លាំងក្លាសំពះម៉ែខ្លួន
ទោះស្តេចចក្រពត្តិគ្រងទ្វីបទាំងបួន អំណាចមាំមួនតែនៅខ្លាចម៉ែ។
ពាក្យមេក្នុងលោកមានច្រើនពេកក្រៃ មេជើងមេដៃមេស្រុកមេស្រែ
ពាក្យមេទាំងនោះប្រដូចនឹងម៉ែ ពាក្យមេហូរហែគឺម៉ែទាំងអស់។
ព្រោះម៉ែជាធំម៉ែអ្នកបង្កើត ម៉ែឱ្យកំណើតម៉ែឱ្យចៅដោះ
ម៉ែបង្ហាត់កូនម៉ែមានចិត្តស្មោះ ម៉ែគឺជាកោះនៃជីវិតកូន ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

# សេដ្ឋកិច្ច និង សីលធម៌

កូនប្រុសសម្លាញ់ម៉ែ កូនប្រាប់ម៉ែថា កូនលំបាកក្នុងការជិះកង់ទៅសាលារៀន កូនទាមទារឱ្យម៉ែទិញម៉ូតូឱ្យកូនជិះ។ ប៉ុន្តែ ម៉ែចង់ឱ្យកូនសម្លឹងមើលសិស្សជាច្រើនទៀត ដែលមិនមានសូម្បីតែកង់ជិះ ពួកគេត្រូវដើរទៅរៀនក្នុងរវាងផ្លូវឆ្ងាយទៀតផង និង ត្រូវដើរត្រឡប់មកផ្ទះវិញជួនកាលក៏ដោយសារមិត្តភ័ក្តិអឺចឹងទៅ ទាំងបាយទឹកនំចំណីពួកគេក៏ខ្សត់ខ្សោយជាងកូនដែរ សំពត់ខោអាវក៏ខ្វះខាត ។ មានក្មេងជាច្រើនទៀតមិនទាំងមានសំណាងបានដើរទៅចូលរៀននឹងគេផង ដោយបញ្ហាជីវភាពក្នុងគ្រួសារមានការខ្វះខាតខ្លាំងជាដើម ។

កូនប្រុសម៉ែត្រូវមើលឱ្យឆ្ងាយ មើលក្នុងរង្វង់ធំ កុំមើលទៅតែលើ ត្រូវមើលក្រោមផង ហើយកុំមើលតែខ្លួនឯង ត្រូវមើលអ្នកដទៃខ្លះផងដែរ ។ មនុស្សដែលមើលតែខ្លួនឯង ក៏រមែង ឃើញតែខ្លួនឯង មិនឃើញដល់



អ្នកដទៃផងទេ យូរៗទៅក៏ក្លាយជាមនុស្សចេះគិតតែពីខ្លួនឯង មិនចេះគិតដល់អ្នកដទៃខ្លះឡើយ យកតែសេចក្តីសុខសប្បាយរបស់ខ្លួនជាទីតាំងប៉ុណ្ណោះ ។

ម៉ែនិងឪពុករបស់កូនបានប្រឹក្សាគ្នាហើយ ចាំដល់កូនចូលមហាវិទ្យាល័យសិន ទើបបានទិញម៉ូតូឱ្យកូន ឥឡូវម៉ែត្រូវការឱ្យកូនលំបាកក្នុងវ័យនេះ វ័យដែលមានកម្លាំងមាំមួន វ័យដែលត្រូវសាងកម្លាំងចិត្តឱ្យរឹងប៉ឹង ខន្តីតស៊ូក្នុងឆាកជីវិត ដើម្បីកូននឹងបាននូវសេចក្តីសុខសប្បាយក្នុងវ័យដែលគួរបានសម្រាក ។

ម៉ែសូមឱ្យកូនបានដឹងផងថា ក្នុងឆាកជីវិតនេះ កូនត្រូវតស៊ូតែម្នាក់ឯងគត់ មិនមែនដូចជាការតស៊ូក្នុងការប្រកួតកីឡាបាល់ទាត់ជាដើមនោះទេ ការប្រកួតកីឡាបាល់ទាត់បើឈ្នះក៏ឈ្នះទាំងក្រុម បើចាញ់ក៏ចាញ់ទាំងក្រុមដែរ ប៉ុន្តែចំពោះឆាកជីវិតនេះវិញ កាលបើកូនចាញ់ចំពោះជីវិតហើយ កូនមិនអាចបន្ទោសអ្នកណាបានឡើយ ហើយមនុស្សគ្រប់គ្នាដែលសម្លឹងមើលកូនជាអ្នកប្រកួតចាញ់ជីវិត

នេះ គេបន្ទោសកូនតែម្នាក់ឯងប៉ុណ្ណោះ បើកូនមានអំណត់អត់ធន់តស៊ូក្នុងឆាកជីវិតបានជោគជ័យ មនុស្សទាំងឡាយគេអាចនឹងលើកតម្កើងដល់មាតាបិតា គ្រូអាចារ្យខ្លះផងដែរ ក្នុងឋានៈជាអ្នកអប់រំទូន្មានប្រៀនប្រដៅចង្អុលប្រាប់ផ្លូវ តែមនុស្សដែលត្រូវបានទទួលការលើកតម្កើងច្រើនជាទីបំផុត ក៏គឺខ្លួនកូនហ្នឹងតែម្តង ។

ការប្រកួតចាញ់ជីវិត ញាតិមិត្តបងប្អូនប្រាកដជាមិនមានអ្នកណាម្នាក់ព្រមចាញ់ឬរួមចាញ់ជាមួយកូនឡើយអស់យ៉ាង គេគ្រាន់តែមើលដោយការអាណិតអាសូរតែប៉ុណ្ណោះ ព្រោះហេតុដូច្នោះ កូនត្រូវហ្វឹកហាត់កសាងកម្លាំងចិត្តឱ្យបានរឹងប៉ឹង ឱ្យចេះអត់ធន់តស៊ូដើម្បីបានជាមូលដ្ឋានដ៏ល្អនៃជីវិតរបស់ខ្លួនឯង ។

កូនម៉ែកុំចេះតែសម្លឹងរកទីពឹងអំពីខាងក្រៅ ឬអំពីមនុស្សដទៃនោះឡើយ កូនត្រូវចេះព្យាយាមធ្វើខ្លួនឱ្យជាទីពឹងនៃខ្លួនឯង ហើយត្រូវតែប្រញាប់ប្រញាល់ ឱ្យបានសមគួរតាមវ័យទៀតផង ។ សូមឱ្យកូនម៉ែបានយល់ឃើញ



ត្រូវដូច្នេះថា ការចេះដឹងល្អ និងការប្រព្រឹត្តល្អ ជារបស់សំខាន់ក្នុងជីវិត ។

ដូចកូនបានឃើញស្រាប់ហើយ ឪពុកម្តាយមិនមែនជាអ្នកមានទ្រព្យសម្បត្តិ រហូតដល់ថ្នាក់ចាយប្រាក់ដោយមិនចាំបាច់គិតមុខគិតក្រោយនោះទេ ឬក៏ត្រូវយកមកបាច-សាចរោយរាយលេង ដើម្បីសេចក្តីសប្បាយរីករាយរបស់កូន ទាំងដែលខ្លួនឯងជាម៉ែឪត្រូវប្រឹងរកស៊ីងលៀនគ្រាប់ភ្នែកនោះឡើយ ដូច្នេះកូនកុំចេះតែគិតប្រាថ្នាក្នុងទ្រព្យសម្បត្តិរបស់ម៉ែឪ ដើម្បីបានយកទៅប្រើប្រាស់ចាយវាយហាក់ដូចជាម៉ែឪរបស់ខ្លួនសម្បូណ៌ណាស់ ឬហាក់ដូចជាបានមកដោយឥតប្រឹងប្រែងនោះ ។

ប្រសិនបើម៉ែមានប្រាក់នឹងទិញម៉ូតូឱ្យកូនជិះ ម៉ែក៏មិនមែនទិញឱ្យដើម្បីកូនរីករាយភ្លើតភ្លើននៅក្នុងពពួកមិត្តភ័ក្តិ នាំគ្នាជិះហ៊ឺហាបណ្តើរស្រីញីទៅឯណេះ ទៅឯណោះវាយឫកអួតក្អេងក្អាងនោះឡើយ រឿងនេះចាំដល់កូនចេញរកប្រាក់ខ្លួនឯង កូននឹងបានដឹងថា ការរកប្រាក់នោះវា





Document Produced by deskPDF Unregistered :: http://www.docudesk.com

មានសេចក្តីលំបាកយ៉ាងណា ហើយកូនចង់បានអ្វីកូននឹងទិញដោយខ្លួនឯងចុះ ។ ចូរកូនចាំទុកថា **មនុស្សណាដែលទន់ខ្សោយមិនអាចយកឈ្នះជីវិតខ្លួនឯងបាន មនុស្សនោះមិនអាចកសាងខ្លួនបានឡើយ** ព្រោះជាអ្នកទ្រាំនឹងគ្រឿងដែលនាំឱ្យត្រេកត្រអាលមិនបាន ។

នៅពេលកូនចេញពីការសិក្សា ហើយចូលទៅធ្វើការនៅក្នុងកន្លែងណាមួយនោះ ចៅហ្វាយនាយគេមើលកិច្ចការងាររបស់កូន ច្រើនជាងសញ្ញាប័ត្ររបស់កូនទៅទៀត កូនត្រូវធ្វើការងារឱ្យល្អ មានសីលធម៌ មានសេចក្តីព្យាយាម មានស្មារតីគ្រប់គ្រងខ្លួន ប្រកបធ្វើតែការងារសុចរិត ពិចារណាមុនហើយទើបធ្វើ មានការសង្រួមប្រយ័ត្នកាយវាចាចិត្តរបស់ខ្លួនជានិច្ច មិននិយាយឡេះឡោះ មិនអួតអាងលើកតម្កើងខ្លួនប្រៀបផ្ទឹមនឹងអ្នកដទៃ **កូនត្រូវជាមនុស្សទន់ភ្លន់ចេះបន្ទន់តិរិយាបថ មិនទុកនូវសេចក្តីល្អរបស់ខ្លួនឱ្យច្រើន** កុំអួតអាងគុណវិសេសអ្វីរបស់ខ្លួនឯង សេចក្តីល្អរបស់យើងនោះទុកឱ្យអ្នកដទៃគេមើលឃើញ គេ



និយាយចុះ កុំចាំបាច់និយាយខ្លួនឯង បើកូនមាននូវគុណសម្បត្តិដូចពោលមកនេះ **កូនត្រូវបានឈ្មោះថា អ្នកមានជីវិតរស់នៅដោយធម៌** ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សរសើរថាជាអ្នកមានសេចក្តីចម្រើន ។

ក្នុងលោកយើងនេះ នៅត្រូវការមនុស្សល្អទៀតច្រើនណាស់ កូនកុំនឹកថាមានត្រឹមតែសញ្ញាប័ត្រជាន់ខ្ពស់ហើយ អាចបានជួបនូវសេចក្តីសម្រេចគ្រប់យ៉ាង តាមតែបំណងប្រាថ្នានោះ ។ កូនត្រូវតែមាននូវគុណសម្បត្តិដទៃផ្សេងទៀតឱ្យបានច្រើន ជាអលង្ការ ទើបកូនអាចមាននូវដំណើរជីវិតប្រព្រឹត្តទៅបានល្អ ។ បើប្រាសចាកនូវគុណសម្បត្តិសេចក្តីល្អផ្សេងៗហើយ ទោះបីមានទ្រព្យច្រើន មានស័ក្តិធំ មានមុខតំណែងខ្ពង់ខ្ពស់ប៉ុនណាក៏ដោយ ក៏មិនអាចមាននូវសេចក្តីសុខដ៏ពិតប្រាកដឡើយ ត្រឹមតែជាការបោកបញ្ឆោតខ្លួនឯងប៉ុណ្ណោះ ហើយត្រូវបញ្ឆោតឱ្យរីករាយរំភើបទៅរហូតក្នុងមួយថ្ងៃៗ រកតម្លៃខ្លឹមសារពិតនៃជីវិតមិនមាន ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

នៅក្នុងសាលាដែលកូនរៀនក៏មានវិជ្ជាសីលធម៌ សូមកូនយកចិត្តទុកដាក់សិក្សាឱ្យមែនទែន **ពិតមែនតែវិជ្ជាព្រះពុទ្ធសាសនា ឬវិជ្ជាសីលធម៌នេះ ដាក់ឱ្យមានការប្រឡងក្នុងសាលាតិចតួចក៏ដោយ ប៉ុន្តែមនុស្សទាំងឡាយគេបានចេញវិញ្ញាសាផ្នែកសីលធម៌នេះផ្ទាល់ក្នុងជីវិតគ្រប់ពេលវេលា ច្រើនជាងវិជ្ជាណាៗទាំងអស់** វិជ្ជានេះមានការចាំបាច់ដល់ដំណើរជីវិតច្រើនជាទីបំផុត ជាការចាំបាច់ដល់ថ្នាក់ខានមិនបានតែម្តង ។

បើមនុស្សយើងរៀនក្នុងសាលា គ្រាន់តែដើម្បីចេញមកប្រកបអាជីពរកស៊ីចិញ្ចឹមជីវិតទេនោះ តើមនុស្សនឹងជាសត្វដ៏ប្រសើរវិសេស ជាងសត្វលោកប្រភេទដទៃទៀត យ៉ាងដូចម្តេចទៅ ? ព្រោះសត្វដទៃសូម្បីមិនបានចូលរៀនក្នុងសាលាក៏អាចមានជីវិតរស់នៅបានដែរ ទាំងដែលពពួកសត្វខ្លះ មើលទៅទំនងជារស់នៅសប្បាយជាងមនុស្សខ្លះទៀតផង ។

ព្រោះអាស្រ័យហេតុនេះ ការសិក្សាទើបគួរឱ្យមាន



ទិសដៅខ្ពង់ខ្ពស់ប្រសើរជាងការសិក្សាដោយត្រឹមតែដើម្បីចិញ្ចឹមជីវិតតែម្យ៉ាងនោះ គឺគួរឱ្យមានទិសដៅទៅក្នុងការអប់រំចិត្ត ដើម្បីឱ្យមានចិត្តខ្ពស់ បានទៅជាមនុស្សចេះព្យាយាមកាត់បន្ថយនូវកិលេស ព្រោះកិលេសវាជាគ្រឿងទាញចិត្តឱ្យធ្លាក់ចុះទាប និងឱ្យថោកដូចវាដែរ ។

សេចក្តីនេះមិនមែនបានន័យថា ការប្រកបមុខរបរចិញ្ចឹមជីវិតមិនសំខាន់នោះទេ ម៉ែដឹងហើយថា បច្ច័យ៤ ជារបស់ចាំបាច់សម្រាប់មនុស្ស ការខ្វះខាតបច្ច័យ៤ ធ្វើឱ្យមនុស្សលំបាក មានការរំខានក្នុងចិត្ត កង្វល់ដល់អនាគត និងមានសេចក្តីដឹងខ្លួនជាទុក្ខក្នុងរឿងផ្សេងៗ ប៉ុន្តែ **ការខ្វះខ្នាយចាយវាយមិនគិត វាក៏ធ្វើឱ្យមនុស្សប្រឈមមុខនឹងទុក្ខកង្វល់បានដែរ** ដូច្នេះកូនត្រូវចេះគិតឱ្យមែនទែន ។

ម៉ែសូមពន្យល់កូនអំពី សីលធម៌និងសេដ្ឋកិច្ចក្នុងជីវិតប្រចាំថ្ងៃ « សេដ្ឋកិច្ចដែលពិតប្រាកដរមែងមិនទាស់នឹងច្បាប់សីលធម៌ ក៏ដូចគ្នាដែរ គឺសីលធម៌ពិតប្រាកដត្រូវតែមានសេដ្ឋកិច្ច ដែលល្អប្រព្រឹត្តទៅព្រមគ្នា » កូន

Document Produced by deskPDF Unregistered :: http://www.docudesk.com

ត្រូវយល់ពាក្យនេះដូចតទៅ :

សេដ្ឋកិច្ចដែលពិតប្រាកដ ត្រូវតែមិនប្រជែងយកប្រៀបលើគ្នា គឺត្រូវធ្វើដោយការលះបង់ ដើម្បីសេចក្តីសុខដល់អ្នកដទៃដែលមានទំនាក់ទំនងជាមួយគ្នា ឃើញអ្នកដទៃប្រហែលៗនឹងខ្លួនឯងដែរ ទើបមិនមានការយកប្រៀបលើគ្នា នេះឯងគឺជាសីលធម៌ដ៏ខ្ពង់ខ្ពស់ កាលបើដូចនេះសីលធម៌ដែលពិតប្រាកដ ត្រូវតែជាសីលធម៌ដើម្បីការរស់នៅដ៏ល្អប្រសើររបស់មនុស្សជាតិ និងដើម្បីសុវត្ថិភាពនៃសង្គមហ្នឹងឯង គឺមិនមែនជាសីលធម៌ដែលអណ្តែតទៅខ្ពស់ផុតពីសេចក្តីពិតនៃជីវិតមនុស្សនោះឡើយ ដូច្នេះ សីលធម៌និងសេដ្ឋកិច្ចត្រូវតែដើរទៅព្រមគ្នា ទើបនឹងឱ្យនូវសេចក្តីសុខសាន្តដល់មនុស្សក្នុងសង្គមទៅបាន ។

សូមឱ្យកូនសាកគិតមើល បើមនុស្សក្នុងសង្គមរបស់យើងមានបាននូវទ្រព្យល្មមប្រើប្រាស់ និងល្មមហូបចុកហើយ ឬក៏ ច្រើនបរិបូណ៌ជាងហ្នឹងទៅទៀតក៏ដោយ តើវាអាចបញ្ចប់នូវបញ្ហាឬ ? តាមពិត មនុស្សក៏នៅតែ



ឈ្លោះគ្នា ដណ្តើមទ្រព្យគ្នា បៀតបៀនសម្លាប់គ្នា ច្រណែនឈ្នានីសគ្នា និងព្យាបាទគ្នាជាដដែល ព្រោះមនុស្សមានក្រពះតណ្ហា ។ បើភ្លៀងធ្លាក់ចុះមកនូវដុំមាស មនុស្សក៏នៅតែកាប់សម្លាប់គ្នាដើម្បីដណ្តើមដុំមាសហ្នឹងឯង ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា សូម្បីភ្នំមាសពីរ ក៏មិនល្មមដល់សេចក្តីត្រូវការរបស់មនុស្សម្នាក់ដែរ គង់តែទៅដណ្តើមនូវភ្នំមាសអ្នកដទៃទៀតជាមិនខាន នេះព្រោះតែការមិនចេះគ្រប់គ្រាន់នៃមនុស្សលោក ។

ព្រោះដូច្នេះ ការសិក្សាត្រូវតែឱ្យមានការចម្រើនផ្លូវចិត្ត លះបង់នូវការលោភលន់ការខឹងក្រោធ និងសេចក្តីល្ងង់ទៅព្រមគ្នាជាមួយនឹងការចម្រើននូវចំណេះដឹង ទើបជាការបានសម្រេចនូវទិសដៅនៃការសិក្សា បើមិនដូច្នោះទេ ការសិក្សានោះឯងនឹងវិលត្រឡប់មកសម្លាប់អ្នកសិក្សាខ្លួនឯងវិញ ព្រោះការសិក្សាដោយគ្រាន់តែដើម្បីបានជាឧបករណ៍នៃកិលេសប៉ុណ្ណោះ របៀបដូចគេចាប់អាសិរពិសត្រង់កន្ទុយអ៊ីចឹងឯង ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

ការប្រព្រឹត្តធម៌ជារបស់ដ៏សំខាន់ក្នុងសង្គមមនុស្ស តែមនុស្សយើងច្រើនតែមើលមិនឃើញសេចក្ដីសំខាន់នេះ ប្រៀបដូចការមើលឃើញភាពល្អស្អាតនៃដើមឈើ តែមើលមិនឃើញនូវឫស ដែលជារបស់ដ៏សំខាន់ក្រៃលែងក្នុងការចម្រើននៃដើមឈើនោះដូច្នោះឯង ។

បើមនុស្សលើផែនដីនេះ អត់អាហារបរិភោគមួយថ្ងៃ វាមិនជាគ្រោះថ្នាក់អ្វីដែលនាំឱ្យស្លាប់នោះឡើយ តែបើមនុស្សគ្រប់គ្នាអត់សីលអត់ធម៌ទៅវិញ ដោយត្រឹមតែមួយភ្លែតប៉ុណ្ណោះ ដូចជាអត់សីល ខទី១ ក្នុងសីល៥ មនុស្សត្រូវសម្លាប់គ្នាស្លាប់រាប់ចំនួនមិនអស់ នាំឱ្យមានសេចក្ដីក្ដៅក្រហាយដ៏ខ្លាំងក្លាកើតឡើង ។ សេចក្ដីនេះជាការបញ្ជាក់ឱ្យឃើញថា ការប្រព្រឹត្តធម៌មានសេចក្ដីសំខាន់ដ៏ក្រៃលែង គឺជាឫសគល់នៃសន្តិសុខក្នុងពិភពលោក ។

ដើម្បីឱ្យកូនបានឃើញនូវសម្បត្តិដ៏មានតម្លៃបំផុតនៅក្នុងជីវិតពិតៗ ម៉ែសូមឱ្យកូនតាំងចិត្តធ្វើជាមនុស្សល្អ ព្យាយាមស្វែងរកចំណេះដឹងមកដាក់ខ្លួន កូនត្រូវប្រើពេល



វេលាឱ្យមានប្រយោជន៍ ដោយការអានសៀវភៅផ្សេងៗ ដូចនេះកូនអាចជជែកជាមួយអ្នកប្រាជ្ញបានគ្រប់គ្នា ដោយការអានសៀវភៅលោក ។ សូមកូនកុំសម្លាប់ពេលវេលាឬផាត់ពេលវេលាចោលឱ្យសោះ បុគ្គលណាសម្លាប់ពេលវេលាជារឿយៗ ពេលវេលានឹងត្រឡប់បែរមកសម្លាប់នូវបុគ្គលនោះវិញ ឱ្យជាមនុស្សស្លាប់ទាំងរស់ ពោលគឺធ្វើឱ្យបុគ្គលនោះឯងរស់នៅយ៉ាងឥតប្រយោជន៍ មានតែបង្កនូវទុក្ខទោសដល់ខ្លួនឯងនិងដល់សង្គមទៀតផង ។

មានមនុស្សចំនួនច្រើនណាស់ ដែលធ្វើការទន្ទឹងតែប្រាក់ខែ បន់ឱ្យតែឆាប់ដាច់ខែនឹងបានបើកប្រាក់ តើគេមាននឹកទេថា មួយខែដែលកន្លងទៅ ជីវិតគឺត្រូវអស់មួយខែ ? តើជីវិតមួយខែ គេកំណត់តម្លៃប៉ុន្មាន ? បានប្រាក់មកតែជីវិតត្រូវអស់ សេចក្ដីស្លាប់ចូលមកជិត គ្រប់ដង្ហើម។

សេចក្ដីល្អដែលត្រូវធ្វើមានច្រើនណាស់ ការងារចិញ្ចឹមជីវិតដែលត្រូវធ្វើក៏មានច្រើនដែរ ធ្វើយ៉ាងណាក៏មិនចេះអស់ តែហេតុដូចម្ដេចហ្ន៎ ? ទើបចេះតែមានមនុស្ស

និយាយថា «មិនដឹងធ្វើអ្វី» ហើយក៏បោះបង់ពេលវេលាចោលគួរឱ្យស្តាយណាស់ ។

ធម្មជាតិបានឱ្យពេលវេលាដល់មនុស្សយើង ស្មើៗគ្នាក្នុងមួយថ្ងៃៗអ្នកណាយកទៅធ្វើអ្វីក៏បាន បើគេប្រើពេលវេលាឱ្យមានប្រយោជន៍ ជីវិតរបស់គេក៏មានប្រយោជន៍។

ក្នុងថ្ងៃនេះ ម៉ែដាស់តឿនកូនបន្ថែមបន្តិចទៀតថា អ្វីដែលកូនចង់បានតាមចំណង់ចិត្តនោះ វាមិនអាចធ្វើឱ្យកូនបានឆ្អែតគ្រប់គ្រាន់ឡើយ ។ របៀបដូចកូនកាលពីមិនទាន់បានកង់ហើយទារម៉ែទិញកង់ដូច្នោះឯង ឥឡូវមិនទាន់បានប៉ុន្មានផង ឃើញថាកូនធុញទ្រាន់នឹងកង់ទៅហើយ បញ្ជាក់ឱ្យឃើញថា កូនខ្វះអំណត់អត់ធន់ ខ្វះការតស៊ូព្យាយាម ខ្វះធម៌សន្តោស ដូច្នេះ កាលបើកូននៅតែខ្វះគុណធម៌ទាំងនេះជារៀងរហូតនោះ កុំនិយាយត្រឹមតែម៉ូតូ ទោះបីជាកូនបានរថយន្ត ក៏កូនមិនឆ្អែតឡើយ។

សូមកូនម៉ែគ្រប់គ្រាន់ក្នុងពេលនេះតែម្តងទៅ។



# គុណសម្បត្តិរបស់ស្ត្រី

របស់របរប្រើប្រាស់ក្នុងផ្ទះ កាលបើមានប្រាក់ល្មមទិញប្រើបានក៏ទិញប្រើទៅ ព្រោះជារបស់ចាំបាច់ក្នុងជីវិតប្រចាំថ្ងៃ មិនគួរកំណាញ់ស្វិតឱ្យជីវិតរស់នៅលំបាកលំបិននោះឡើយ ម្យ៉ាងទៀតមិនត្រូវខ្ជះខ្ជាយរហូតដល់ទៅថ្នាក់មិនដឹងតម្លៃសម្បត្តិទ្រព្យ មិនដឹងតម្លៃមាសប្រាក់ដែលរកបានមកដោយលំបាកនោះទេ ។

ការរៀបចំជីវិតឱ្យរស់នៅ ក្នុងរវាងកណ្តាលនៃសេចក្តីកំណាញ់ និងការខ្ជះខ្ជាយនេះឯង គឺជាការងាររបស់មនុស្សមធ្យ័ត។ មនុស្សមធ្យ័តគឺជាមនុស្សដែលរៀបចំជីវិតឱ្យឋិតនៅត្រង់កណ្តាលនៃសេចក្តីមិនល្អផ្សេងៗ ។

គុណធម៌គ្រប់យ៉ាង រមែងមានការប្រព្រឹត្តទៅជាផ្លូវកណ្តាលទាំងអស់ ព្រោះដូច្នេះ បើកូនត្រូវការកព្វូននូវគុណធម៌របស់ខ្លួន ក៏សូមឱ្យកូនកាន់យកផ្លូវកណ្តាលតួយ៉ាងដូចជាសេចក្តីក្លាហាន ត្រូវតែនៅរវាងការភ័យខ្លាច





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ផ្តេសផ្តាសនិងការព្រហើនកោងកាច សេចក្តីក្លាហាននេះ ទើបជាគុណធម៌ ឬដូចជា សេចក្តីព្យាយាមដែលនៅកណ្តាលរវាងការខ្ជិលនិងការប្រឹងជ្រុល សេចក្តីព្យាយាមនេះទើបជាគុណធម៌ ។ល។

កូនបានប្រាប់ម៉ែថា សិស្សរួមថ្នាក់របស់កូនខ្លះ គេមានការរស់នៅដោយការចាយវាយខ្ជះខ្ជាយ សប្បាយរីករាយ មាននូវទ្រព្យសម្បត្តិ និងមនុស្សដែលតាមបម្រើ សេចក្តីត្រូវការច្រើនសន្ធឹកសន្ធាប់ ចង់ទៅលេងឯណាក៏ទៅបាន ចង់បរិភោគអ្វីក៏បរិភោគបាន ចំណែកកូនមិនអាចធ្វើយ៉ាងនេះបានឡើយ ។

ម៉ែមានការពេញចិត្ត និងសប្បាយចិត្តនៅត្រង់ដែលកូនមិនអាចធ្វើដូចនោះបាន ។ ការធ្វើតាមតែចិត្តខ្លួនឯង និងការបានសព្វគ្រប់តាមតែចិត្តចង់ក្នុងវ័យបឋមនោះ នឹងសាងឧបនិស្ស័យមិនល្អក្នុងខ្លួនក្មេង កាលបើឧបនិស្ស័យបែបនេះមាំទាំក្នុងសន្តាន ក៏រមែងមានផលអាក្រក់ទៅខាងចុង តាមតែកម្លាំងនៃឧបនិស្ស័យមិនល្អ



នេះឯង ម៉ែសូមឱ្យកូនចេះគិតខ្លាចរឿងនេះក្នុងជីវិតផង។

ក្មេងៗសព្វថ្ងៃដោយច្រើននៅតាមទីក្រុង និយមហ៊ឺហា ចូលចិត្តដើរលេងឥតប្រយោជន៍ សប្បាយរីករាយចាយប្រាក់ឥតគិត មិនចូលសាលាមិនចូលផ្ទះ មានគ្នីគ្នាប្រុសស្រីផ្តេសផ្តាស ក្មេងប្រុសចេះផឹកស្រាជក់បារីបណ្តើរស្រីបំផ្លាញប្រាក់ ។ល។

ម៉ែឪនៅតាមខេត្ត បញ្ជូនកូនស្រីខ្លះ ប្រុសខ្លះឱ្យមករៀននៅភ្នំពេញ មានកូនដែលមិនចេះអាណិតដល់ម៉ែឪរបស់ខ្លួន យកប្រាក់មកដើរលេងភ្លើតភ្លើន ហើយប្រាប់ទៅម៉ែឪថាប្រាក់មិនគ្រប់ ព្រោះត្រូវការរៀនច្រើន ម្ល៉ោះហើយម៉ែឪត្រូវប្រឹងរកប្រាក់បែកញើសហូរញើស ទ្រាំខាំធ្មេញអត់ធ្មត់ដើម្បីឱ្យកូនបានរៀនបន្ត ពេលខ្លះត្រូវបង្ខំពេកក៏លក់ស្រែលក់ចំការ លក់គោ លក់ក្របីក៏មាន ។ កូនខ្លះល្ងង់ដូចក្របី ចចេសដូចឆ្មា ម៉ែឪអន់ចិត្តលាន់មាត់ពោលថា «លក់គោឱ្យក្របីរៀន» ក្របីមែនៗនៅគ្រាន់បើជាងនោះបីល្ងង់ម្តេចម្តា ក៏គង់អាចប្រើបានជាគ្នាទាញនង្គ័ល ឬ

អួសរទេះ ប៉ុន្តែកូនដែលល្ងង់នោះ គិតតែបំផ្លាញប្រាក់ម៉ែឪ ទោះបីម៉ែឪ ឬក៏ លោកគ្រូ អ្នកគ្រូខំទូន្មានប្រៀនប្រដៅយ៉ាងណាក៏ដោយ ក៏នៅតែប្រហែលគ្នានឹងនិយាយឱ្យឆ្មាស្តាប់ បង្ករឿងរំខានមិនចេះចប់។

កូនស្រីម៉ែ ម៉ែសូមឱ្យកូនស្រីមានសួស្តីសិរីភទ្រតាមធម្មជាតិ គឺជាស្រីដែលមាននូវគុណសម្បត្តិរបស់ស្រី ល្អប្រសើរក្នុងភាពជាស្រី គួរឱ្យស្រឡាញ់ព្រោះមានសភាពជាស្រី មានខ្លួនសង្រួមជានិច្ច មានសេចក្តីសប្បាយរីករាយនៅក្នុងភាពជាស្រីល្អតាមធម្មជាតិ ។ កូនស្រីមិនចាំបាច់លេងខ្លួនឆើតឆាយខ្លាំងពេក រហូតដល់បាត់បង់នូវសម្បត្តិចរិយារបស់ខ្លួនជាស្រីនោះឡើយ ។

កូនស្រីម៉ែត្រូវហ្វឹកហាត់អប់រំខ្លួន ឱ្យបានជាមនុស្សមាំទាំ រៀបចំជីវិតទៅតាមឋានៈឱ្យបានសមរម្យដល់ខ្លួនឯងប្រៀបបីដូចជាផ្កាយ ដែលមានគោចរទៅតាមវិថីរបស់ខ្លួនមិនមែនជាស្លឹកឈើជ្រុះ ដែលចេះតែរសាត់ទៅតាមខ្យល់បក់ផាត់នោះទេ ។ មនុស្សប្រភេទផ្កាយនេះមានតិចក្នុង



លោក ប៉ុន្តែច្រើនតែបានជួបប្រសព្វនូវសេចក្តីសម្រេចដ៏ប្រពៃក្នុងជីវិត បានទទួលសេចក្តីសុខដ៏ប្រណីតសុខុម មានសន្តិភាពក្នុងចិត្ត និងជាតួយ៉ាងដ៏ល្អប្រសើររបស់អ្នកដែលត្រូវការសេចក្តីសុខក្នុងផ្នែកនេះ ។

មនុស្សស្លឹកឈើជ្រុះ គឺស្រេចហើយតែលោកធម៌នាំទៅ រសាត់ទៅតាមសម័យនិយមនៅក្នុងសង្គម រហូតដល់បាត់បង់អស់នូវខ្លឹមសារពិតរបស់ខ្លួនឯង រវល់តែវង្វេងជាមួយនឹងអ្វីដែលជាសំបកក្រៅ មិនដឹងថាអ្វីដែលជាគុណតម្លៃពិត និងអ្វីដែលគ្រាន់តែជារបស់ក្លែងក្លាយឡើយ ។

រឿងទាំងអស់នេះ មិនមែនមានតែចំពោះក្នុងក្រុមក្មេងៗនោះទេ មនុស្សធំមនុស្សចាស់ក៏ដូចគ្នា កុំនឹកថាជាមនុស្សធំហើយ ចាស់ហើយវារមែងល្អទៅឯង ។ មនុស្សដែលមិនសិក្សាធម៌ មិនបដិបត្តិធម៌ មិនអប់រំខ្លួនឱ្យនៅក្នុងសេចក្តីសង្រួម រឹងរឹតតែធំប៉ុនណា កិលេសដែលវាមានទម្លាប់ជាឧបនិស្ស័យ ក៏ចម្រើនធំធាត់ឡើងប៉ុណ្ណឹងដែរ ។ ច្រើនដោយលាភយស សេចក្តីសរសើរ និងការលើក





Document Produced by deskPDF Unregistered :: http://www.docudesk.com

តម្កើងហើយ ថាបើដឹងមិនទាន់ មិនឃើញទោសទេ ក៏ជាការបើកឱកាសចំហផ្លូវ ឱ្យកិលេសហូរចូលមកនៅក្នុងចិត្តសន្តានណែនក្រាស់ក្រៃលែង ដូចជាការលើកតម្កើងខ្លួន ការវង្វេងនឹងខ្លួនឯង ការមិនព្រមទទួលយកសេចក្ដីពិត ចាយវាយខ្ជះខ្ជាយ ប្រកួតប្រជែងសម្ដែងខ្លួន ឫស្យាឈ្នានីស មាយាលាក់ពុត អំនួតអួតអាងសព្វគ្រប់បែបយ៉ាងជាដើម ។

កិលេស និងសេចក្ដីអាក្រក់ក្នុងខ្លួននឹងកាត់បន្ថយទៅបាន គឺចំពោះតែអ្នកដែលបានសិក្សាធម៌ បដិបត្តិធម៌យ៉ាងត្រឹមត្រូវ ព្រមទាំងអប់រំខ្លួនឯងឱ្យតាំងនៅក្នុងសេចក្ដីសង្រួមតែប៉ុណ្ណោះ ។

ម៉ែសូមឱ្យកូនបានយល់ចូលចិត្តថា ទម្លាប់គឺជាឧបនិស្ស័យក្នុងសន្តាន មិនថាផ្លូវល្អឬផ្លូវអាក្រក់ឡើយ វារមែងដូចជាព្រៃ ដែលចេះតែដុះច្រើនឡើងក្រាស់ឡើងកាន់តែច្រើនថ្ងៃ គឺកាន់តែណែនក្រាស់ កាលបើកូនបានដឹងយ៉ាងនេះហើយ សូមកូនអប់រំហ្វឹកហាត់ខ្លួនឱ្យធ្លាប់ទៅ

-៥៣-

តែក្នុងផ្លូវល្អ កុំទម្លាប់ក្នុងផ្លូវមិនល្អឡើយ ។

បើកូនចង់តាមតែចិត្តខ្លួនឯង ដោយការចាយវាយខ្ជះខ្ជាយមិនគិត ដើរលេងសប្បាយរីករាយហ៊ឺហា ម៉ែសូមឱ្យកូន នឹកដល់មនុស្សជាច្រើននាក់ទៀតក្នុងប្រទេសយើង ដែលមានភាពក្រីក្រលំបាក ខ្វះខាតអាហារបរិភោគ ខ្វះខាតសម្លៀកបំពាក់ ខ្វះខាតផ្ទះសម្បែង និងខ្វះខាតថ្នាំកែរោគ ព្រមទាំងខ្វះអ្នកជួយមើលថែទៀតផង ។

សូមកូនកុំមើលតែខ្លួនឯង ម៉ែសូមឱ្យកូនមើលទៅមនុស្សជុំវិញខ្លួនផង រួចហើយមើលឱ្យទូលំទូលាយទៅឆ្ងាយ កូននឹងឃើញពួកមនុស្សដែលរួមកើតក្នុងលោកជាមួយយើង កំពុងមានសេចក្ដីទុក្ខលំបាកពាសពេញផែនដី ។

ជីវិតរស់នៅរបស់មនុស្សយើង មានទុក្ខច្រើនមានសេចក្ដីចង្អៀតចង្អល់ច្រើន ម្យ៉ាងទៀត ជីវិតម្នាក់ៗក៏មិនយឺនយូរប៉ុន្មានដែរ ព្រោះដូច្នេះ ម៉ែសូមឱ្យកូនមាននូវសេចក្ដីព្យាយាម អត់ធន់ក្នុងការសិក្សា អត់ធន់ក្នុងការងារដែលជាមុខនាទីរបស់ខ្លួន កុំឱ្យពេលវេលាកន្លងទៅដោយ

-៥៤-



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ឥតប្រយោជន៍ឡើយ ។ បើនៅក្នុងវ័យសិក្សាបែរជាមិនចង់សិក្សារៀនសូត្រ រវល់តែចង់សប្បាយរីករាយក្នុងការដើរលេង ដល់វ័យធ្វើការក៏រកការងារអ្វីប្រាកដប្រជាមិនបាន ម្ល៉ោះហើយក៏បានទៅជាមនុស្សមិនថ្លៃថ្នូរដូចបុរាណ-ភាសិតបានពោលថា « អ្នកបួសមិនសង្រួមមិនល្អ គ្រ-ហស្ថឥតរបរមិនថ្លៃថ្នូរ » លុះដល់វ័យចាស់ក៏ដល់នូវសេចក្តីលំបាកដោយប្រការផ្សេងៗ ។ ម៉ែនិយាយនេះមិនរួមដល់ជីវិតនៃអ្នកដែល មិនមាននូវឱកាសបានសិក្សារៀនសូត្រព្រោះហេតុណាមួយនោះឡើយ គឺម៉ែនិយាយចំពោះតែក្មេងដែលមានឱកាសហើយ តែមិនព្រមឆក់ឱកាសនោះទុក បណ្តោយឱ្យឱកាសកន្លងទៅ ដោយមិនអាចឱ្យវិលត្រឡប់មកវិញបាន ។

សេចក្តីព្យាយាមនោះ សូម្បីយើងត្រូវមានការហត់នឿយខ្លះក្នុងកាលខាងដើម តែយើងនឹងបានផលល្អ ហើយរីករាយនៅខាងចុង ប្រៀបដូចយើងស្រោចទឹកដើមឈើនៅគល់ ប៉ុន្តែ មានផលនៅខាងចុងដូច្នោះឯង។



កូនម៉ែត្រូវមានខន្តីជាទឹក មានចិត្តនឹងធឹងជាដី ដើម្បីជួយផ្គងឱ្យសេចក្តីព្យាយាមប្រព្រឹត្តទៅបានស្មើល្អ ។ កូនកុំធ្វើអ្វីហ៊ឺហាខ្លាំងក្លាបានតែមុនដំបូង របៀបដូចភ្លើងឆេះចំបើងនោះ កូនត្រូវពិចារណាចំពោះការងារជាមុន ឱ្យហើយស្រេច ឃើញថាសមគួរដល់ខ្លួនហើយ កូនត្រូវតែអត់ធន់ និងព្យាយាមធ្វើ រហូតដល់បានទទួលនូវសេចក្តីសម្រេចតាមដែលបានគិតទុក ។

កាលបើកូនបានជួបប្រសព្វនូវសេចក្តីសម្រេចក្នុងរឿងមួយហើយ រមែងជាហេតុនាំឱ្យកូនបានជួបប្រសព្វនូវសេចក្តីសម្រេចក្នុងរឿងដទៃច្រើនមុខទៀត នេះព្រោះអាស្រ័យសេចក្តីព្យាយាម និងសេចក្តីអត់ធន់ពីខាងដើមហ្នឹងឯង ប៉ុន្តែម៉ែសូមដាស់តឿនកូនថា ទោះបីកូនបានជួបប្រសព្វនូវសេចក្តីសម្រេចច្រើនមុខយ៉ាងណាក៏ដោយ សូមកុំឱ្យកូនតម្កើងខ្លួន សូមឱ្យកូនចេះគោរពអ្នកដទៃឱ្យបានត្រឹមត្រូវ បន្ទាបកាយបន្ទន់ចិត្តជានិច្ច ។ បើកូនធ្វើបានដូចនេះ កូនមិនមានផ្លូវនៃសេចក្តីវិនាសឡើយ នឹងមានតែ

សេចក្ដីចម្រើន ច្រើនឡើង ៗ ។

និយាយមកដល់ត្រង់នេះ ម៉ែមានសេចក្ដីសង្ស័យកើតឡើងថា ដូចម្ដេចបានជាសិស្សសាលាចំនួនច្រើន បានជួបគ្រូហើយ ហួសទៅដោយមិនសម្ដែងការគោរពចំពោះគ្រូ ជួបគ្រូទីណាក៏ធ្វើហាក់ដូចជាមិនស្គាល់ មិនមានការរាក់ទាក់គួរសមតាមបែបសិស្សនឹងគ្រូអ្វីសោះអីចឹង ឬក៏គេខ្មាសថាគ្រូរបស់គេមានការឱនថយយ៉ាងនេះមួយ យ៉ាងនោះមួយ ។ ក្នុងរឿងនេះ ចំពោះគ្រូមិនជាអ្វីឡើយ តែសេចក្ដីសាបសូន្យនឹងធ្លាក់ទៅលើសិស្សនោះជាពិតប្រាកដយ៉ាងហោចណាស់ ក៏សាបសូន្យនូវគុណសម្បត្តិម្យ៉ាងក្នុងខ្លួនទៅហើយដែរ ។

ម៉ែសូមឱ្យកូនជាមនុស្សទន់ភ្លន់ទាំងកាយទាំងចិត្តគោរពដឹងគុណគ្រូស្មើដើមស្មើចុង កូនម៉ែត្រូវតែជាមនុស្សមានគុណសម្បត្តិឱ្យបានគ្រប់គ្រាន់ ដូចពាក្យចាស់បានពោលថា « ងើយស្កក ឱនដាក់គ្រាប់ » ។ មែកក្រូចដែលមានផ្លែក្នុងចំការ ហាក់ដូចជាបន្ទាបខ្លួនគោរពមនុស្ស



គ្រប់គ្នាដែលដើរទៅមក ចំណែកមែកក្រូចដែលងាប់ ឬកួរស្រូវដែលស្កករឹងក្រញាង មើលទៅមិនមានភាពល្អល្អះគួរឱ្យរីករាយដូចជាមែកដែលមានផ្លែ ឬ កួរស្រូវដែលដាក់គ្រាប់នោះឡើយ ។

ការទន់ភ្លន់ឱនលំទោន និងឫកពាសុភាពរាបសាមិនមែនជាគ្រឿងសំគាល់នៃភាពទន់ខ្សោយ ដោយប្រការណាមួយទេ តាមពិត គឺជាគ្រឿងសំគាល់នៃភាពរឹងប៉ឹងមាំមួន ដែលជាលក្ខណៈនៃមនុស្សល្អ សូមកូនចាំទុកថា :

ទន់ភ្លន់ចំពោះអ្នកស្មើគ្នា ជាមនុស្សសុភាពរាបសា

ទន់ភ្លន់ចំពោះអ្នកទាបជាង ជាមនុស្សមានចិត្តខ្ពស់

ទន់ភ្លន់ចំពោះមនុស្សទូទៅ ជាអ្នកផុតចាកភ័យ។

កាលបើយ៉ាងនេះ ដូចម្ដេចបានជាសិស្សត្រូវទន់ភ្លន់ជាមួយលោកគ្រូអ្នកគ្រូ ដែលជាអ្នកខ្ពស់ជាងខ្លួនមិនបាននោះ ? បើថាមើលឃើញគាត់ទាបជាងខ្លួនដោយទ្រព្យសម្បត្តិជាដើម ការទន់ភ្លន់ចំពោះគាត់ក៏សម្ដែងថាជាអ្នកមានគុណធម៌ខ្ពស់ ឬមានចិត្តខ្ពស់ សូម្បីមិន





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

បាននឹកថាជាគ្រូអាចារ្យរបស់ខ្លួនទេ គ្រាន់តែជាមនុស្សទូទៅ ការទន់ភ្លន់ចំពោះគាត់ក៏នាំឱ្យរួចផុតពីភ័យដែរ។

បើកូនម៉ែមានភាពទន់ភ្លន់ ចេះគោរពឱ្យបានសមគួរតាមឋានៈ កូនម៉ែមានតែសេចក្តីចម្រើន ដោយចំពោះគឺកូនស្រី គួរទន់ភ្លន់បន្ទន់កាយរៀបរយឬកពាឱ្យបានប្រពៃមែនទែន រីឯរឹតតែសុភាពទន់ភ្លន់ច្រើនប៉ុនណា ក៏រីងរឹតតែមានតម្លៃច្រើនប៉ុណ្ណោះ កូនកុំនឹកច្រឡំថា គុណសម្បត្តិបែបនេះ វាហួសសម័យទៅហើយនោះ តាមពិតគុណសម្បត្តិបែបនេះ គឺត្រូវការជាចាំបាច់បំផុត ព្រោះជារបស់ក្រកម្ររកបានក្នុងសម័យសព្វថ្ងៃនេះឯង ។

ឪពុករបស់កូនធ្លាប់បាននិយាយថា ស្ត្រីជាធនធានមនុស្សដ៏មានគុណតម្លៃច្រើនបំផុត ច្រើនរហូតដល់ទៅមិនដឹងថាប្រមាណប៉ុនណា ។ ស្ត្រីជាធនធានដ៏ល្អក្រៃលែងជាងទ្រព្យសម្បត្តិដែលមនុស្សយើងមាន ។ ស្ត្រីជានិមិត្តរូបនៃសេចក្តីអត់ធន់ ការលះបង់ខ្ពស់ និងភាពទន់ភ្លន់ស្រគត់ស្រគំនឹងនួនសុភាពរាបសា ។ ស្ត្រីជាកម្លាំងចិត្ត ។



ស្ត្រីមានតម្លៃជាងថ្ងៃសៅរ៍ថ្ងៃអាទិត្យ ឬក៏ ថ្ងៃដទៃទៀតដែលជាថ្ងៃឈប់សម្រាកពីការងារ ។ ស្ត្រីជាអ្នកលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីមនុស្សដែលខ្លួនស្រឡាញ់ ដូចជាបុត្រធីតាឬក៏ស្វាមី មានសេចក្តីអត់ធន់យ៉ាងខ្ពស់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យបានរស់ដល់ធំ មានការគ្រប់គ្រងទៅលើការបរិភោគ ការសម្រាក ការសិក្សារៀនសូត្រជាដើមរបស់កូន មានការទទួលខុសត្រូវក្នុងរឿងគ្រួសារសព្វគ្រប់ អាចធន់ទ្រាំទទួលទុក្ខបានច្រើនរឿង ក្នុងពេលដែលបុរសជាស្វាមីចេញទៅភ្លើតភ្លើនរីករាយជាមួយមិត្តភ័ក្តិ ជាមួយសុរា ជាមួយនារីដទៃ ។ល។ ពុកកូនបាននិយាយបញ្ជាក់ដល់រឿងនេះថា គាត់ធ្លាប់ឃើញមេសុនខនិងមេឆ្មាអត់ធន់ចិញ្ចឹមកូនយ៉ាងគួរឱ្យអាណិត ក្នុងពេលវេលាដែលឈ្មោលបានទុកកូនឱ្យហើយ ក៏លះបង់ចោលមេបាត់ទៅ ។ មនុស្សប្រុសដែលមានសភាពដូចជាសុនខនិងឆ្មាឈ្មោលក៏មានមិនតិចនៅក្នុងលោក ប៉ុន្តែដែលឪពុកកូនបានពោលមកនេះ មិនមែនបានសេចក្តីថា ស្ត្រីសុទ្ធតែ

ល្អក្រៃលែងទៅទាំងអស់គ្រប់គ្នានោះទេ ដែលជាមនុស្សស្រីមិនល្អថោកថយក៏មានដែរ ព្រោះការប្រព្រឹត្តខុសអំពីលក្ខណៈរបស់ស្ត្រី ។

សូមកូនម៉ែយល់ដឹងថា ឱ្យតែជាមនុស្ស ទោះជាប្រុស ឬស្រីសុទ្ធតែល្អប្រសើរតាមធម្មជាតិទាំងអស់ ព្រោះកំណើតមនុស្សកើតអំពីកុសលកម្ម ប៉ុន្តែដែលមានមនុស្សមិនល្អនោះ ដោយសារខ្វះស្មារតីគ្រប់គ្រងខ្លួនហ្នឹងឯង ។

ឪពុករបស់កូន មិនយល់ស្របក្នុងរឿងប្រកួតបវរកញ្ញាគ្រប់ប្រភេទ ចំណែកម៉ែក៏ដូចគ្នា ព្រោះយល់ឃើញថា វាជាការទម្លាយយសសីរបស់ស្ត្រីទៅវិញទេ ។ នាងមិនគួរព្រមខ្លួន ចូលមកជាគ្រឿងលេងរបស់សង្គមឡើយ នាងមិនមែនជាបក្សីតូច ក្នុងទ្រុងមាសដែលដើរ ដែលឈរ ឱ្យមនុស្សជ្រើសរើសថាមួយណាល្អដាច់គេ ហើយក៏ចងបូឱ្យទៅនោះទេ ។ សូម្បីនាងបានទទួលតំណែងលេខ១ ប្រចាំប្រទេស ឬប្រចាំពិភពលោកក៏ដោយ ក៏មិនមែនពិតជាថានាងល្អបំផុតក្នុងប្រទេស ឬ ក្នុងពិភពលោកនោះ



ឡើយ ព្រោះនៅមានស្ត្រីដែលល្អជាងនាងច្រើនណាស់ ដែលគេមិនព្រមចូលមកប្រកួត មិនព្រមដាក់ខ្លួនឱ្យទៅជាគ្រឿងលេងរបស់សង្គម ។ ម៉ែយល់ថា កិច្ចការនេះគួរតែមិនចាំបាច់ឱ្យមានក្នុងសង្គមឡើយ ។

ថ្ងៃនេះ ម៉ែបានពន្យល់កូនវែងឆ្ងាយណាស់ហើយ កូនចូលចិត្តស្តាប់ពាក្យឪពុកម្តាយទូន្មាន ធ្វើឱ្យឪពុកម្តាយមានសេចក្តីសុខក្នុងចិត្ត ។

ម៉ែសូមឱ្យពរដល់កូន សូមឱ្យកូនម៉ែសម្បូណ៌ទៅ ដោយគុណសម្បត្តិដូចបានពោលហើយ នុ៎ះគឺជាសេចក្តីសុខរបស់ម៉ែ ហើយក៏ជាពរ ដែលកូនគប្បីជូនត្រឡប់ឱ្យមកដល់ឪពុកម្តាយរបស់កូនវិញដែរ ។





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

## ឱវាទម៉ែចុងក្រោយ

បើកូនម៉ែ ព្យាយាមហាត់អត់ធន់ចំពោះរឿងបន្តិចបន្តួចបន្ទាប់បន្សំបាន ក៏មិនចាំបាច់ត្រូវទៅអត់ធន់ក្នុងរឿងធំៗដែរ ។ មានរឿងដែលគួរឱ្យប្លែកមួយក្នុងមនុស្សយើង គឺ មានមនុស្សមិនតិចនាក់ឡើយ ដែលមិនអាចអត់ធន់ចំពោះពាក្យសិកសៀតចាក់ដោត និងការមើលងាយពីអ្នកដទៃបាន រហូតដល់ទៅសម្លាប់គេ ប៉ុន្តែ បែរទៅជាចេះអត់ធន់នៅក្នុងគុកបានដល់ទៅ១០ឆ្នាំ ២០ឆ្នាំ ឬអាចមួយជីវិតបានទៀតផង ។

មនុស្សខ្លះមិនដល់ថ្នាក់សម្លាប់គេទេ តែបែរទៅជានាំយកពាក្យសិកសៀតជាដើមនោះ មកសម្លាប់សេចក្តីសុខរបស់ខ្លួនឯងទៅវិញ។ តាមពិតនោះ បើយើងមិនយកវាមកទុកក្នុងចិត្តហើយ យើងនឹងរស់នៅជាមួយសេចក្តីស្ងប់។ ក្នុងលោកនេះ មិនមានការរស់នៅជាមួយនឹងអ្វីឱ្យប្រសើរដូចជាការរស់នៅជាមួយនឹងសេចក្តីស្ងប់ឡើយ ។



ដើម្បីសេចក្តីស្ងប់កើតមានក្នុងចិត្ត កូនត្រូវតែចេះអត់ធន់ តែកុំចេះអត់ធន់របៀបដូចគោ ដូចក្របីនោះ ត្រូវតែរៀនឱ្យឆ្លាតផង ទើបអាចកសាងសេចក្តីស្ងប់ទៅបាន ។

កូនត្រូវស្គាល់តម្លៃនៃសេចក្តីល្អគ្រប់យ៉ាង ចំពោះសេចក្តីល្អ ទោះជាអ្នកណាដឹងអ្នកណាឃើញ ឬមិនបានដឹងមិនបានឃើញក៏ដោយ អ្នកណាលើកតម្កើងឬមិនលើកក៏ដោយ បានលាភបានយស ឬអត់ក៏ដោយ គឺជាសភាវៈដែលគួរតែធ្វើហ្នឹងឯង **ព្រោះសេចក្តីល្អជារង្វាន់ដែលត្រូវទទួលបានស្រេចទៅហើយ** ។

អាវតែមួយ កាលដែលចោរពាក់ គឺជាអាវចោរ មនុស្សទាំងឡាយគេស្អប់ខ្ពើម កាលបើអ្នកចិត្តបុណ្យពាក់ក៏ជាអាវរបស់អ្នកចិត្តបុណ្យ មនុស្សទាំងឡាយគេបូជា ។ ទីកន្លែងតែមួយ កាលបើមនុស្សអាក្រក់គេអាស្រ័យនៅ គឺជាកន្លែងដែលគួរឱ្យរង្កៀសខ្លាច លុះដល់មនុស្សល្អចូលទៅនៅអាស្រ័យវិញ ទីនោះក៏ក្លាយទៅជាបូជនីយដ្ឋាន ។

មនុស្សយើងមានឆ្អឹង មានសាច់ មានឈាមដូចគ្នា

Document Produced by deskPDF Unregistered :: http://www.docudesk.com

ប៉ុន្តែ មនុស្សទាំងឡាយគេមាក់ងាយ ឬបូជា គឺស្រេចហើយតែចិត្តដែលអាស្រ័យនៅក្នុងកាយហ្នឹងឯង កាលបើសេចក្តីពិតច្បាស់លាស់យ៉ាងនេះហើយ ចូរកូនម៉ែជ្រើសរើសយកដោយខ្លួនឯងចុះ ថាតើត្រូវធ្វើយ៉ាងណា ។

សេចក្តីសុខតាមផ្លូវលោក ក្រេបផឹកយូរទៅរឹតតែសាបដូចបរិភោគអំពៅពីគល់ទៅរកចុងអ៊ីចឹងឯង ចំណែកសេចក្តីសុខតាមផ្លូវធម៌វិញរឹងរឹតតែក្រេបផឹក រឹងរឹតតែផ្អែមឡើង របៀបដូចបរិភោគអំពៅពីចុងដេញមករកគល់ ព្រោះហេតុនេះទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា « សច្ចៈហ្នឹងឯងដែលមានរសគាប់ប្រពៃលើអស់រសទាំងពួង » ឬម្យ៉ាងទៀតថា « រសព្រះធម៌រមែងឈ្នះអស់រសទាំងពួង » ។

មនុស្សដែលមិនបានសិក្សាអំពីសេចក្តីល្អ សូម្បីតែរបស់ដែលល្អប្រាកដចំពោះមុខ ក៏មិនចេះចាប់យកមកទុកឡើយ កុំចាំបាច់និយាយដល់ការស្វែងរក ចំណែកអ្នកដែលបានទទួលនូវការសិក្សាយល់អំពីសេចក្តីល្អ រមែងមិនលះ



បង់ចោលនូវសេចក្តីល្អដែលប្រាកដនៅចំពោះមុខផង និងស្វែងរកសេចក្តីល្អដទៃៗទៀតផង។ អ្នកស្វែងរកល្អ រមែងបានជួបល្អ អ្នកស្វែងរកអាក្រក់ រមែងបានជួបអាក្រក់ ។

ត្រូវការជាសេដ្ឋី តែមិនចេះសន្សំទ្រព្យ ត្រូវការជាមនុស្សល្អ តែមិនចេះសន្សំសេចក្តីល្អ ទាំងពីរយ៉ាងនេះតើអាចបានយ៉ាងដូចម្តេចទៅ ?

ភ័យវិបត្តិដែលកើតអំពីអ្នកដទៃ ឬ កើតអំពីខាងក្រៅ នៅមានផ្លូវការពារបាន ព្រោះខ្លួនឯងក៏មិនបានរួមដៃជាមួយនឹងភ័យវិបត្តិនោះ ខំប្រឹងការពារ ឬក៏រត់គេចញាតិមិត្តបងប្អូនក៏ល្មមអាចនឹងជួយការពារបាន ចំណែកភ័យវិបត្តិដែលកើតអំពីខ្លួនឯង ពោលគឺកើតពីការធ្វើរបស់ខ្លួនវិញនោះ ការពារបានដោយលំបាកណាស់ ព្រោះខ្លួនឯងក៏មិនបានតស៊ូការពារ ថែមទាំងរួមដៃទៀតផង តើអ្នកណានឹងអាចជួយបាន ដូច្នេះ ឧបនិស្ស័យអាក្រក់ដែលកើតឡើងក្នុងខ្លួននោះឯង គប្បីឃើញថាជាភយន្តរាយដ៏កាចសាហាវរបស់ខ្លួន ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

មនុស្សដែលជ្រមុជជ្រមុលនៅក្នុងលោក លិចចុះនៅក្នុងលោក លំបាកនឹងធ្វើនូវប្រយោជន៍ឱ្យដល់សង្គមលោកបានណាស់ ព្រោះគេឃើញតែពីខ្លួនឯង សម្លឹងមើលតែប្រយោជន៍ និង សេចក្ដីសុខផ្ទាល់ខ្លួនប៉ុណ្ណោះ ម្ល៉ោះហើយ អ្វីដែលជាប្រយោជន៍ផ្ទាល់ខ្លួន សូម្បីដឹងថាត្រូវធ្វើអាក្រក់ហើយក៏នៅតែពេញចិត្តធ្វើដែរ ចំណែកអ្វីដែលជាប្រយោជន៍អ្នកដទៃវិញ សូម្បីដឹងថា ត្រូវធ្វើល្អហើយក៏មិនចង់ធ្វើដែរ ។ មនុស្សដែលជ្រមុជជ្រមុលក្នុងលោក មិនចេះមានការលះបង់ពិតប្រាកដទេ គេចេះតែលះបង់បែបបិទនុយនឹងផ្លែសន្ទូចស្ទូចត្រីតែប៉ុណ្ណោះឯង ។

បុគ្គលដែលឃើញកាលវែង គួរហាត់ឱ្យចេះមានការលះបង់បន្តិចម្ដងៗ គឺជាការសាងនិស្ស័យ ឧបនិស្ស័យ និងអធ្យាស្រ័យល្អឱ្យដល់ខ្លួនឯង និស្ស័យនេះនឹងចាក់ឫសសន្សឹមៗចូលជ្រៅទៅក្នុងសន្ដាន បានជាឧបនិស្ស័យដ៏មាំ-ទាំខ្លាំងក្លា ។ ការលះបង់ ការចេះអើពើ និងការជួយសង្គ្រោះ បានរីកផ្សាយទូលំទូលាយក្នុងសន្ដានចិត្ត រហូត



អាចធ្វើនូវអ្វីដែលមនុស្សទាំងឡាយ ធ្វើបានដោយលំបាក ដូចជា ព្រះបរមពោធិសត្វ ក្រោយមកបានជាព្រះសម្មា-សម្ពុទ្ធ ព្រះអង្គទ្រង់លះបង់គ្រប់យ៉ាងដើម្បីសេចក្ដីល្អ និងដើម្បីសេចក្ដីសុខនៃសង្គមសត្វលោកទាំងមូល ។

ធ្វើជាមនុស្សត្រូវចេះនឹកដល់មាតាបិតា គ្រូអាចារ្យ ញាតិមិត្តបងប្អូន រហូតដល់អ្នកទាំងឡាយផ្សេងទៀតដែលរាប់អានខ្លួនផង បើយើងធ្វើនូវអំពើអាក្រក់ រហូតដល់ខូចកេរ្តិ៍ឈ្មោះ វិនាសទាំងខ្លួនទៀតនោះ តើលោកអ្នកទាំង-ឡាយនោះ នឹងត្រូវខូចចិត្តយ៉ាងណាទៅ ដោយចំពោះដ៏ក្រៃលែង គឺមាតាបិតា លោកមានការខូចចិត្តច្រើនជាងអ្នកណាៗទាំងអស់ ព្រោះលោកបានចិញ្ចឹមមើលថែដោយការនឿយហត់លំបាក លោកទាំងពីរ បានលះបង់ទាំងកម្លាំងកាយ កម្លាំងទ្រព្យ កម្លាំងសតិបញ្ញា និងកម្លាំងចិត្តទាំងអស់ សំដៅទៅក្នុងការបណ្ដុះបណ្ដាលកូន តាំងសេចក្ដីសង្ឃឹមថា នឹងបានរីករាយជាមួយសេចក្ដីល្អរបស់កូន ប៉ុន្តែត្រឡប់ជាបានស្ដាប់ បានឮតែរឿងអាក្រក់របស់

កូន តើលោកមានការខកចិត្តប៉ុនណាទៅ តើជាការចាក់ទម្លុះទម្លាយចិត្តរបស់លោកដ៏មានគុណយ៉ាងណាទៅ ។

ហៃកូនប្រុសស្រីទាំងឡាយអើយ សូមកូនជួយម៉ែឱ្យបានសម្រេចបំណង ដែលជាទិសដៅនៃការអប់រំចិញ្ចឹមកូន គឺសូមឱ្យកូនបានជាមរតកដ៏សំខាន់បំផុត ជាមរតកដែលម៉ែត្រូវប្រគល់ឱ្យដល់ប្រទេសជាតិ និងពិភពលោក ។

កាលបើម៉ែបំពេញនូវតួនាទីរបស់ខ្លួនបានសម្រេច ដោយកូនម៉ែបានជាមនុស្សល្អហើយ ម៉ែក៏មានសេចក្ដីសុខ ព្រោះសមតាមបំណងដែលបានគិតទុក តាំងពីកូននៅក្នុងផ្ទៃម៉ែម្ល៉េះ ។

ម៉ែសូមយកចិត្តដ៏បរិសុទ្ធស្មោះ ជាចិត្តដែលបានពលីចំពោះកូនគ្រប់បែបយ៉ាង មកឱ្យពរដល់កូន សូមឱ្យកូនបានជួបប្រទះតែនឹងសេចក្ដីសុខ និងសូមឱ្យកូនបានដើរតាមស្នាមនៃអ្នកប្រាជ្ញ រហូតដល់ផុតចាកទុក្ខទាំងពួង ។

**ពីបំណងល្អរបស់ម៉ែ**



## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការងារធម្មទាន

| | |
|---|---|
| ១-ឧបាសក សំរ៉ែង វណ្ណ | ២-ឧបាសក យន្ត សួន |
| ៣-ឧបាសក គួង លាងផេង | ៤-ឧបាសក មួង យេន |
| ៥-ឧបាសក រស់ សូផាត | ៦-ឧបាសក គុយ សុធន |
| ៧- នាង ជា សុណារី | ៨- នាង យុន សូនីម៉ា |
| ៩-ឧបាសិកា ហួន ចាន់បូដា | ១០-ឧបាសក វ៉ាន់ ខុនណា |





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយធម៌ប្រចាំឆ្នាំ

១. ឧបាសក យូស៊ាង.ងួនលី និង ឧបាសិកា លីម.ឃីម

២. ឧបាសក ឆាយ.អ៊ីវស៊ាង និងឧបាសិកា ហុង.គឹមសែ

៣. ឧបាសក ឆាយអ៊ីវ.ស្រេងលីម និងឧបាសិកាហួត.ឃីម

៤. ឧបាសក ហៃ.ប៊ុនណារិន និងឧបាសិកាអោង.ស៊ីថាន់

៥. ឧបាសក ហៀប.បេ និងឧបាសិកា ឡៅ.កែវម្លិះ

៦. ក្រុមឧបាសក ឈុំ.កុសល និងឧបាសក អ៊ុន.ឆាយត្រី

៧. ក្រុមឧបាសក លឹម .ស៊ាង ( ហៅ ទូច )

៨. ឧបាសក យន្ត. សួន និងភរិយា ព្រមទាំងបុត្រ

៩. ឧបាសក ប៊ុន.ហេង ឧបាសិកា ជុំ.សុខុម ព្រមទាំងបុត្រ

១០. ឧបាសិកា ឱម.លក្ខណា ព្រមទាំងបុត្រ

១១. ឧបាសិកា ញឹក.ប៊ុនថា និងឧបាសិកា ម៉ែន.សុភារី

១២. ឧបាសិកា ច័ន្ទ.បុប្ផាណា ព្រមទាំងបុត្រ

១៣. ឧបាសក ម៉ែន ច័ន្ទត្រីស្នា ឧបាសិកា ស្វួន កល្យាណ

១៤. ឧបាសិកា ស្វួន ចរណៃ

១៥. ឧបាសិកា អ៊ា នៅ ព្រមទាំងបងប្អូនកូនចៅ (កាណាដា )

១៦. ឧបាសក អ៊ុត .ឆៃវ៉ាន និងភរិយា ព្រមទាំងបុត្រ



១៧. ឧបាសក ប្លោក .ងួនថៃ និងភរិយា ព្រមទាំងបុត្រ

១៨. ក្រុមឧបាសក មួង .យេន (វត្តសំពៅមាស )

១៩. ក្រុមឧបាសក ផាន់. សារី

២០. ឯកឧត្តម អ៊ិត.ប្រាំង និងលោកជំទាវ ញ៉ែម.សេដ្ឋា

២១. ឧបាសិកា ជី.ឡាង

២២. ឧបាសកម៉ៅ.សុគន្ធ ឧបាសិកាអ៊ឹង.យ៉េកហួយព្រមទាំងបុត្រ

២៣. ឧបាសិកា អ៊ឹង.យ៉េកសាង ព្រមទាំងបុត្រ

២៤. ឧបាសិកា ហេង.ស៊ីវខេង និងម្តាយឈ្មោះ អៀង.ហ្គិច

២៥. លោក យឹម.ស៊ីមុន្នី និងអ្នកស្រី យូ.ប៉ូលីន ព្រមទាំងបុត្រ

២៦. ឧបាសក ឡាយ.សុខុម ឧបាសិកា សួន.ចន្ថា និងបុត្រ

២៧. ឧបាសក ងឹម.ញាណ ឧបាសិកា កាំង.ប៉ូលីន និងបុត្រ

២៨. ឧបាសិកា អ៊ុំ.អ៊ន់

២៩. ឧបាសិកា ប៉ូអាន.ស៊ីវត្ថា

៣០. ឧបាសិកា ប៉ូផាវ៉ាណ

៣១. ឧបាសិកា សាក់.ស៊ាងអេង

៣២. ឧបាសិកា ជា.ផាត ព្រមទាំងបុត្រ

៣៣. ឧបាសក ប៉ុល.នាង ឧបាសិកា គ្រៀល.ស៊ីយ៉ា និងបុត្រ

៣៤. ឧបាសិកា គា.ស៊ីន

៣៥. ឧបាសិកា អ៊ឹង . ស៊ីវន

៣៦. ឧបាសកអ៊ុក-សាម៉ាណារ៉ា ឧបាសិកាហ៊ាប-តេង និងបុត្រ

៣៧. ឧបាសក ម៉ៅ-ស្រ៊ិន ឧបាសិកា ទូច-ស៊ីនហ៊ន និងបុត្រ

៣៨. ឧបាសក ពុធ-ប៉ោលាង ឧបាសិកា ហ៊ុន-ស៊ីវអៀង

៣៩. ឆែមសុក្រឹត +ពុធគន្ធា Chhem Sokreth et Puth Kunthea

៤០. ឧបាសក ម៉ែន-សឿន ឧបាសិកា អៀង-ណារី និងបុត្រ

៤១. ឧបាសក ឯម ភក្តី និងមាតា ហេង ប៉ូវស្រីនាថ

៤២. ឧបាសិកា ចំណាន ព្រមទាំងក្រុមគ្រួសារ

៤៣. ឧបាសិកា លី វន ព្រមទាំងក្រុមគ្រួសារ

៤៤. ឧបាសក ហួន ប៉ាន់ និងឧបាសិកា ថៃ នាថ ព្រមទាំងបុត្រ

៤៥. លោក ស៊ា រស់ និងអ្នកស្រី ញ៉េប ដារ៉េត ព្រមទាំងបុត្រ

៤៦. លោក រឿង សេដ្ឋា និងអ្នកស្រី នាង ជួនអេងព្រមទាំងបុត្រ

៤៧. លោក សែន-សុវណ្ណរិទ្ធ និងភរិយា

៤៨. ឧបាសក ប៉ូច ប៉ូរី ព្រមទាំងបុត្រ

៤៩. ឧបាសិកា អៀ-កេសរ ព្រមទាំងគ្រួសារ

៥០. លោកតា តាន់-ឈីវហា និងលោកយាយ ស៊ូ-ចិន្ត្រា

៥១. ឧបាសិកា តែ-សាយជូ ព្រមទាំងកូនចៅ

៥២. ឧបាសិកា តាន់-ជាលី និងពុទ្ធបរិស័ទខេត្តសៀមរាប

៥៣. ឧបាសិកា ឯម សុខន ព្រមទាំងកូន និងចៅ

៥៤. ឧបាសិកា ប៊ិល-យ៉ែម



៥៥. ឧបាសិកា កង-ភឹម

៥៦. ឧបាសិកា ម៉ក់-នាង

៥៧. មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ខេត្តពោធិសាត់

៥៨. ក្រុមពុទ្ធបរិស័ទនៅទីក្រុងស៊ីតនី ប្រទេសអូស្ត្រាលី

៥៩. ក្រុមពុទ្ធបរិស័ទចិត្តបុណ្យក្នុងសហគមន៍ធម្មទាន

**បោះពុម្ព ៤០.០០០ ក្បាល**

**សម្រាប់ជាធម្មទាន**





Document Produced by deskPDF Unregistered :: http://www.docudesk.com

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌
## ព្រះពុទ្ធសាសនា
## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត_ក្រុង | ពេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -05h00 mn<br>-18h00 mn<br>-19h00 mn<br>-19h30 mn<br>-20h00 mn<br>-20h30 mn | -FM 99 MHz<br>-FM 95 MHz<br>-AM 918 MHz<br>-FM 97 MHz<br>-FM 98 MHz<br>-FM 96 MHz |
| ក្រុងព្រះសីហនុ | -06h00 mn<br>-13h00 mn | -FM 92 MHz |
| ខេត្តបាត់ដំបង | -06h00 mn<br>-06h30 mn<br>-18h00 mn<br>-18h30 mn<br>-19h30 mn | -FM103.2MHz<br>-FM 96 MHz<br>-FM 91 MHz<br>-FM 96 MHz<br>-FM103.2MHz |
| ក្រុងប៉ៃលិន | -18h00 mn | -FM 90.5MHz |
| ខេត្តសៀមរាប | -18h30 mn | -FM100.5MHz |
| ខេត្តពោធិសាត់ | -06h00 mn | -FM 98.5MHz |
| ខេត្តកំពត | -18h30 mn | -FM103.5MHz |
| ខេត្តកំពង់ចាម | -05h30 mn | -FM100.5MHz |

**ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ**

-៧៥-

## សៀវភៅដែលរៀបរៀងដោយ
## ខ្ញុំព្រះករុណា ខ្ញុំបាទ
## ✍ ប៊ុត_សាវង្ស ✍

១. ម៉ែ
២. ជំនួយសតិភាគ ១ ដល់ភាគ៧
៣. មនុស្សជាមួយនឹងការងារ
៤. សិក្ខាបទមនុស្សល្អ
៥. ពរ៤ប្រការ
៦. ព្រះពុទ្ធភាសិត ៤៣គាថា
៧. ខ្លឹមសារគួរយល់ដឹង
៨. ព្រះពុទ្ធសាសនា
៩. កូនមាសឪពុក

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង ។

-៧៦-



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

# មកដល់កូនប្រុសសម្លាញ់មាសឪពុក

ឪពុកប្រាថ្នាឱ្យកូនប្រុសជាប្រុសពិតៗ ជាមនុស្សចេះលះបង់ មានសេចក្តីអត់ធន់ រឹងប៉ឹងស្វាហាប់ មានអធ្យាស្រ័យតស៊ូ ព្យាយាមហើយឆ្លាត មិនលះបង់ចោលនូវមុខនាទី ជាមួយគ្នាផងដែរ ឪពុកសូមឱ្យកូនជាមនុស្សសុភាពរាបសា មានចរិយាទន់ភ្លន់ ។

មនុស្សដែលសុភាពរាបសា មានចរិយាទន់ភ្លន់ មិនមែនបានសេចក្តីថា ជាមនុស្សទន់ខ្សោយនោះទេ ។ ក្នុងទំនងដូចគ្នា មនុស្សដែលរឹងប៉ឹងស្វាហាប់ មិនមែនបានសេចក្តីថា ជាមនុស្សកាចសាហាវ ប្រាសចាកនូវគុណសម្បត្តិរបស់មនុស្សនោះឡើយ ។ កូនត្រូវនាំយកនូវគុណសម្បត្តិទាំងពីរប្រការនេះ មករួបរួមបញ្ចូលគ្នាហើយឱ្យតាំងនៅក្នុងខ្លួនកូនឱ្យបានកុំខាន គឺរឹងប៉ឹង ស្វាហាប់មានអំណត់អត់ធន់ និង សុភាពរាបសាចរិយាទន់ភ្លន់ ចេះក្រែងចិត្តអ្នកដទៃ ដោយចំពោះទៅលើសុភាពស្ត្រី ។



កូនប្រុសមាសឪពុក កូនត្រូវចេះក្រែងចិត្តសុភាព-ស្ត្រីឱ្យច្រើន ត្រូវបដិបត្តិឱ្យបានល្អ មានសភាពទន់ភ្លន់ និងសុភាពរាបសាជាទីបំផុត ព្រោះស្ត្រីភេទជាភេទដែលល្អ-ល្អះល្អិតល្អន់ទន់ភ្លន់ដោយធម្មជាតិ ជាភេទដែលត្រូវការភាពស្រទន់ ការថ្នាក់ថ្នម និងការយកចិត្តទុកដាក់ដោយល្អ តែទាំងនេះសូមកូនកុំយល់ខុសថា ស្ត្រីជាភេទដែលទន់ខ្សោយឱ្យសោះ ព្រោះទៅតាមសេចក្តីពិតហើយនោះស្ត្រីមានសេចក្តីអត់ធន់ មានការលះបង់ដ៏យ៉ាងខ្ពង់ខ្ពស់នេះគឺឪសំដៅយកស្ត្រីដែលល្អ ជាស្ត្រីដែលបានអប់រំបន្ទុំឧបនិស្ស័យក្នុងគុណធម៌ទាំងឡាយ ។

ការមានគភ៌ត្រូវពពោះ៩ខែប្លាយក្តី ការឆ្លងទន្លេសម្រាលកូនក្តី សឹងមានការលំបាកលំបិនដ៏យ៉ាងខ្លាំងក្លាជាការសម្តែង ដល់សេចក្តីអត់ធន់ដ៏យ៉ាងខ្ពង់ខ្ពស់របស់ស្ត្រីប៉ុន្តែ ក៏មានសេចក្តីសោមនស្សរីករាយ កប់សៀតជាមួយសេចក្តីលំបាកផងដែរ ព្រោះដឹងខ្លួនថា បានធ្វើម៉ែ ។

តើមានអ្នកណាខ្លះទៅនៅក្នុងលោកនេះដែលមាន

សេចក្តីអត់ធន់ និងលះបង់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យដូចជាម៉ែ ។ សេចក្តីដែលឪពុកនិយាយនេះ យ៉ាងហោចណាស់ក៏គង់មានស្ត្រីម្នាក់ជាព័ស្តុតាង ដែលល្មមនឹងឱ្យឪយកជាសំអាងបាន គឺម៉ែរបស់កូនហ្នឹងឯង ។

ឪពុកនិយាយរឿងនេះ ដើម្បីឱ្យកូនជាក់ច្បាស់នៅក្នុងចិត្ត ចំពោះភារកិច្ចដ៏សំខាន់របស់ស្ត្រីភេទ ដើម្បីកូនប្រុសបានបដិបត្តិ ទៅរកដោយសុភាពរាបសានិងទន់ភ្លន់។ កូនមិនត្រូវធ្វើអ្វីតាមតែចិត្តខ្លួនឯងនឹកចង់នោះទេ មិនត្រូវឃើញតែពីបានមកខ្លួនដោយមិនចេះទទួលខុសត្រូវ និងមិនត្រូវសម្លុត គំរាម កំហែងទឹកចិត្តរបស់ស្ត្រីនៅពេលដែលមានទំនាក់ទំនងនឹងគ្នានោះឡើយ ។

ទោះជាយ៉ាងណាក៏ដោយ កូនគង់តែនៅមានការទាក់ទងគ្នាជាមួយនឹងស្ត្រីជារឿងរហូតតទៅក្នុងជីវិត បើមិនផ្នែកណាមួយទេ ក៏ផ្នែកណាមួយទៀតដែរ ហើយជាធម្មតាតទៅខាងមុខ កូនក៏ត្រូវរៀបការមានប្រពន្ធ គឺជាការរស់រួមសុខទុក្ខជាមួយស្ត្រីណាម្នាក់ ដែលកូនសម្រេច



ចិត្តជ្រើសរើសយកជាគូប្រចាំជីវិត ។

ការយកប្រពន្ធជាការសម្រេចចិត្តដ៏ធំមួយក្នុងជីវិត ព្រោះហេតុដូច្នេះ កូនប្រុសកុំប្រញាប់ប្រញាល់យកដោយឥតគិតគូរនោះ ត្រូវមើលឱ្យល្អ គិតឱ្យសព្វគ្រប់សិន ។

នៅមានការសម្រេចចិត្តដ៏សំខាន់មួយទៀត គឺការសម្រេចចិត្តជ្រើសរើសការងារចិញ្ចឹមជីវិត កូនត្រូវជ្រើសរើសឱ្យសមនឹងឧបនិស្ស័យ ព្រមទាំងជំនាញរបស់ខ្លួនផងដើម្បីជាហេតុឱ្យកូនចេះស្រឡាញ់ក្នុងការងារនោះឯង ។

កូនមាសឪពុក កូនត្រូវជាមនុស្សនឹងធឹង កុំឡេះ-ឡោះចំពោះការងារ កូនត្រូវចាំទុកថា ការងារល្អដែលកូនបានធ្វើ គឺជាគុណតម្លៃនៃជីវិតរបស់កូន ។ ជាបន្តទៅឪសូមឱ្យកូនទាំងប្រុសទាំងស្រីសិក្សាអំពីម៉ែ និងស្តាប់ឱវាទរបស់ម៉ែ ដោយការយកចិត្តទុកដាក់ជាទីបំផុត ។

**ភ្នំពេញ ថ្ងៃ១៥កើត ខែផល្គុន ព.ស.២៥៤៦**

**ពីឪពុករបស់កូន**



Document Produced by deskPDF Unregistered :: http://www.docudesk.com